**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**


ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Dec-2011, 12:15
CMS/CFO: Sann Rada


**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ស្តីពី អញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស*)**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីការពារក្តី៖**

អាង ឧត្តម

Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រីម ជាប្រធាន**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម យ៉ា ណារិន**

**ចៅក្រម Motoo Noguchi**

**ចៅក្រម Agniezska KLONOWIECKA-MILART**

**ចៅក្រម Chandra Nihal N. Jayasinghe**

**ចៅក្រមបម្រុង ស៊ិន រិទ្ធី**

**ចៅក្រមបម្រុង** Florence MUMBA

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew T. CAYLEY

**ក្រុមមេធាវីជនជាប់ចោទទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សូមដាក់បណ្តឹងសាទុក្ខនេះប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពី អញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងអនុគ្រោះទោស*) ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[១]។ បណ្តឹងសាទុក្ខនេះត្រូវបានដាក់ជាការចាំបាច់ ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ព្រមទាំងបានបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានសម្រេចថា ទាំងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* និងទាំងការលើកលែងទោស និងការអនុគ្រោះទោសរបស់លោក អៀង សារី ("ព្រះរាជក្រឹត្យ")[២] មិនអាចរារាំងការចោទប្រកាន់របស់លោក អៀង សារី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទេ។

## I. មូលដ្ឋាននៃបណ្តឹងសាទុក្ខ

**ក.** *ការអនុគ្រោះទោស ការពារជនជាប់ចោទ ឲ្យរួចផុតពីការអនុវត្តទោស ដោយផ្អែកលើការប្រព្រឹត្តិដែលត្រូវបានលើកលែងទោស។ គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ការពារជនជាប់ចោទ ឲ្យរួចផុតពីការជំនុំជម្រះជាថ្មី ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដោយផ្អែកលើការប្រព្រឹត្តិដដែល ដូចគ្នាទៅនឹងការប្រព្រឹត្តិដែលជាបញ្ហាចោទនៅក្នុងការជំនុំជម្រះកាលពីពេលមុន។ លោក អៀង សារី ត្រូវបានជំនុំជម្រះនៅក្នុងឆ្នាំ ១៩៧៩ ចំពោះការប្រព្រឹត្តិដដែល ដែលជាបញ្ហាចោទនៅក្នុងសវនាការនាពេលបច្ចុប្បន្ន ហើយគាត់បានទទួលការលើកលែងទោស ចំពោះការផ្តន្ទាទោសដែលមាននៅក្នុង*

---

[១] សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស*) ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E51/15។

[២] ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៩៦។

*សាលក្រមរបស់គាត់នាឆ្នាំ១៩៧៩* [៣]*។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសដែរឬទេ ដោយខ្លួនខកខានមិនបានអនុវត្តការលើកលែងទោសដែលលោក អៀង សារី បានទទួល និងគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem) ដើម្បីរារាំងមិនឲ្យមានការចោទប្រកាន់នាពេលបច្ចុប្បន្ននេះមកលើរូបគាត់?*

ខ. *រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាប្រទានសិទ្ធិ ថ្វាយព្រះមហាក្សត្រក្នុងការអនុគ្រោះទោស។ នៅក្នុងឆ្នាំ១៩៩៦ ព្រះមហាក្សត្រទ្រង់បានប្រទានការអនុគ្រោះទោសដល់ លោក អៀង សារី ចំពោះរាល់អំពើ ដែលគាត់បានប្រព្រឹត្តនៅក្នុងអំឡុងពេលយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ តើអង្គជំនុំជម្រះមានកំហុសដែរឬទេ ដែលមិនបានអនុវត្តព្រះរាជក្រឹត្យអនុគ្រោះនៅ អ.វ.ត.ក នេះ?*

## II. សេចក្តីសង្ខេបនៃនីតិក្រឹត្យ

១. អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រលំក្នុងការយល់ឃើញថា សាលក្រមឆ្នាំ១៩៧៩ សម្រេចផ្តន្ទាទោសទៅលើ លោក អៀង សារី មិនមែនជាសេចក្តីសម្រេចមួយ ដែល "ត្រឹមត្រូវ អាចអនុវត្តបាន និងជាស្ថាពរ" នោះទេ។ អង្គជំនុំជម្រះសាលាដំបូង មិនមានសមត្ថកិច្ចដើម្បីកំណត់ថាតើសេចក្តីសម្រេចរបស់តុលាការមួយផ្សេងទៀត មានសុពលភាព ឬយ៉ាងណានោះទេ។ លើសពីនេះទៀត បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងមានសមត្ថកិច្ចក្នុងការសម្រេចបែបនោះក៏ដោយ ក៏សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចមួយត្រឹមត្រូវ អាចអនុវត្តបាន និងជាស្ថាពរដែរ។ សាលក្រមនេះត្រូវបានចេញដោយតុលាការប្រជាជនបដិវត្តន៍ អាចអនុវត្តបាននៅពេលដែលសាលក្រមនេះត្រូវបានដាក់ចេញ និងក្លាយជាស្ថាពរ ដោយសារលោក អៀង សារី មិនបានទាមទារឲ្យពិនិត្យសាលក្រមឆ្នាំ ១៩៧៩ ឡើងវិញទេ និងបើទោះបីជាធ្វើការទាមទារនាពេលនោះ ក៏ការពិនិត្យឡើងវិញលើសាលក្រមឆ្នាំ១៩៧៩ មិនអាចប្រព្រឹត្តទៅបានឡើយ។

---

[៣] សាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍, ឯកសាររបស់អង្គការសហប្រជាជាតិ លេខ A/34/491 ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ ("សាលក្រមឆ្នាំ១៩៧៩")។ លោក អៀង សារី ត្រូវបានជំនុំជម្រះ និងជាប់ចោទ *ដោយកំបាំងមុខ* នៅឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍។ *សូមមើល* ឧបសម្ព័ន្ធ៖ សាវតារ។

២. អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំ ដោយខកខានមិនបានអនុវត្តការលើកលែងទោស ឬ គោលការណ៍*អាជ្ញាអស់ជំនុំ (res judicata)* និងគោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* ដែលគោលការណ៍ទាំងអស់នេះ អាចនឹងរារាំង លោក អៀង សារី ពីការចោទប្រកាន់នាពេលបច្ចុប្បន្ននេះបាន។ ព្រះរាជក្រឹត្យលើកលែងទោស ផ្តល់ជូនលោក អៀង សារី នូវសិទ្ធិឲ្យរួចផុតពីការផ្តន្ទាទោសចំពោះអំពើទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងការជំនុំជម្រះក្តីនាឆ្នាំ១៩៧៩។ គោលការណ៍ *អាជ្ញាអស់ជំនុំ (res judicata)* ដូចមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CPC”) មិនមានករណីលើកលែងនោះទេ។ គោលការណ៍នេះរារាំងការចោទប្រកាន់ទាំងឡាយចំពោះករណីមានសេចក្តីសម្រេចរបស់តុលាការលើកមុន ពាក់ព័ន្ធជាមួយនឹងបណ្តាភាគី និងអំពើដដែល ដូចជារឿងក្តីនាពេលបច្ចុប្បន្ននេះ។ គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ICCPR”) អាចយកមកអនុវត្តក្នុងគ្រប់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក និងរារាំង លោក អៀង សារី ឲ្យរួចផុតពីការចោទប្រកាន់របស់អង្គជំនុំជម្រះមួយនេះ។

៣. អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការដើម្បីសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យលើកលែងទោស**ទេ**។ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្ត *ហួសពីសិទ្ធិអំណាចរបស់ខ្លួន (ultra vires)* ដោយបានសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យលើកលែងទោស។

៤. “ប្រទេសកម្ពុជាមិនជាប់កាតព្វកិច្ចដាច់ខាត ក្នុងការធានាអំពីការចោទប្រកាន់ ឬការផ្តន្ទាទោសចារីនៃអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ អំពើប្រល័យពូជសាសន៍ និងការធ្វើទារុណកម្មនោះទេ។ **បើទោះជា**មានកាតព្វកិច្ចបែបនោះ ក៏កាតព្វកិច្ចនេះមានលក្ខណៈខុសគ្នា និងអាចនឹងជំនួសដោយសិទ្ធិក្នុងការផ្តល់ និងលើកស្ទួយដល់ការអនុគ្រោះពីការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនេះដែរ។

៥. អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវតែអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទៅតាមគោលជំហររបស់ច្បាប់ មិនមែនទៅតាមដំណើរវិវឌ្ឍន៍ តាមការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ អនុញ្ញាតិឲ្យមានការអនុគ្រោះទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានា។

៦. ព្រះរាជក្រឹត្យលើកលែងទោសអាចយកមកអនុវត្តនៅ អ.វ.ត.ក ដោយមិនមានការរំលោភបំពានកាតព្វកិច្ច ក្នុងការចោទប្រកាន់ទៅលើអំពើឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានានោះទេ ព្រមទាំងផ្តល់ឲ្យជនរងគ្រោះនូវសិទ្ធិទទួលបាននូវសំណងប្រកបដោយប្រសិទ្ធភាពទៀតផង។ ការស៊ើបអង្កេតរបស់សំណុំរឿង ០០២ ត្រូវបានបញ្ចប់រួចទៅហើយ។ ព្រះរាជក្រឹត្យលើកលែងទោសអនុវត្តបានចំពោះតែលោក អៀង សារី ប៉ុណ្ណោះ។ ដោយសំណុំរឿង ០០២ មានជាប់ពាក់ព័ន្ធនឹងជនជាប់ចោទផ្សេងៗទៀតនោះ ព្រះរាជក្រឹត្យលើកលែងទោស មិនបានរារាំងការចោទប្រកាន់នានាបណ្តាលមកពីអំពើទាំងឡាយ ដែលត្រូវបានអះអាងថាបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ (“DK”) នោះទេ។ រយៈពេលប្រាំមួយថ្ងៃនៅមុនពេលប្រកាសឲ្យប្រើប្រាស់ព្រះរាជក្រឹត្យលើកលែងទោសនោះ លោក អៀង សារី បានបោះពុម្ពផ្សាយឯកសារមួយដែលមានចំណងជើងថា៖ “ការពិតអំពីរបបផ្តាច់ការរបស់ ប៉ុល ពត” (The True Fact about Pol Pot‟s Dictatorial Regime) ដែលបានបង្ហាញពីការទទួលខុសត្រូវចំពោះជនរងគ្រោះ និងជំនួយក្នុងការស្វែងរកការពិត។ ព្រះរាជក្រឹត្យលើកលែងទោសនោះ បានបញ្ចប់សង្គ្រាមស៊ីវិលមួយដែលបានអូសបន្លាយអស់រយៈ ១៧ ឆ្នាំ។

## III. បញ្ហាបឋមនានា

### ក. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

៧. ពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល វិធាន ១០៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងថា៖

១. អង្គជំនុំជម្រះតុលាការកំពូល ត្រូវសម្រេចលើបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ឬ

ខ. កំហុសនៃអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ

មានភាពមិនយុត្តិធម៌។

បន្ថែមពីលើនេះ បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អាចធ្វើទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រលំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ។

...

៤. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដូចខាងក្រោមត្រូវបានបើកផ្លូវឲ្យប្តឹងសាទុក្ខភ្លាមៗ៖

ក. សេចក្តីសម្រេចដែលអាចមានអនុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី...

៨. មូលដ្ឋាននៃបណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងកំហុសលើអង្គច្បាប់ ព្រមទាំងការរំលោភបំពានឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដោយហេតុថា អង្គជំនុំជម្រះខកខានមិនបានអនុវត្តព្រះរាជក្រឹត្យលើកលែងទោស ដើម្បីរារាំងការចោទប្រកាន់ទៅលើលោក អៀង សារីទេ។ កំហុស និងការរំលោភបំពានឆន្ទានុសិទ្ធិ នេះ មិនមែនគ្រាន់តែជាការភ័ន្តច្រលំលើការយល់ឃើញផ្អែកអង្គហេតុ ឬការអនុវត្តវិធាននៃច្បាប់ដែលមានចែងមិនបានត្រឹមត្រូវនោះទេ។ ជាងនេះទៅទៀត ក៏នៅមានកំហុសពាក់ព័ន្ធទៅនឹងសេចក្តីសន្និដ្ឋានលើអង្គច្បាប់មិនត្រឹមត្រូវ និងការរំលោភបំពានឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃព្រះរាជក្រឹត្យលើកលែងទោសរបស់លោក អៀង សារី ផងដែរ។ មូលដ្ឋានបណ្តឹងសាទុក្ខនានា អាចទទួលយកបាន អនុលោមតាមវិធាន ១០៤(១) និងវិធាន ១០៤(៤)(ក)។ កំហុសទាំងនេះមានអនុភាពអាចមោឃភាពសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះបាន។ ដោយហេតុថា ការចោទប្រកាន់ទៅលើលោក អៀង សារី គួរតែត្រូវបានលើកលែងដោយត្រឹមត្រូវស្របតាមច្បាប់ នោះកំហុសទាំងនេះធ្វើឲ្យមានភាពមិនយុត្តិធម៌ និងធ្វើឲ្យប៉ះពាល់លោក អៀង សារី។

៩. សេចក្តីសម្រេចដែលត្រូវបានជំទាស់ **អាចនឹង**ត្រូវបានប្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក)។ ប្រសិនបើគ្មានកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងទេនោះ កិច្ចដំណើរការនីតិវិធី

អាចនឹងត្រូវបានរំលត់បាត់ទៅហើយ។ វាមិនមែនជាការសមហេតុសមផលនោះទេចំពោះការលើកឡើងនូវទឡ្ហីករណ៍ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានធ្វើការសម្រេចលើបញ្ហានេះបានត្រឹមត្រូវ នោះ ក.ស.ព អាចបានដាក់បណ្ដឹងសាទុក្ខភ្លាមៗ ប៉ុន្តែ ដោយសារតែបញ្ហានេះមិនត្រូវបានសម្រេចដោយត្រឹមត្រូវ មេធាវីការពារក្ដីមិនមានសិទ្ធិក្នុងការទទួលបានដំណោះស្រាយរហូតដល់ក្រោយពេលដែលមានសាលដីកានោះ។ ដើម្បីគោរពគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីគ្នា មេធាវីការពារក្ដីចាំបាច់ត្រូវតែប្រើសិទ្ធិដើម្បីប្ដឹងសាទុក្ខឲ្យបានភ្លាមៗ[៤]។

១០. ប្រសិនបើ ចំពោះករណីដូចដែលមេធាវីការពារក្ដីបានលើកឡើង គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (ne bis in idem)* អាចយកមកអនុវត្តបាននៅក្នុងរឿងក្ដីនាពេលបច្ចុប្បន្ននេះនោះ សិទ្ធិរបស់លោក អៀង សារី ក្នុងការរួចផុតពីការជំនុំជម្រះជាលើកទីពីរចំពោះការប្រព្រឹត្តដដែល នឹងត្រូវរំលោភបំពាន ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូល មិនធ្វើការសម្រេចចំពោះបញ្ហានេះ នៅមុនពេលមានសវនាការជំនុំជម្រះសំណុំរឿងលោក អៀង សារី។ លើសពីនេះទៀត លោក អៀង សារី មិនត្រូវឲ្យគេបង្ខំជាចាំបាច់ឲ្យចូលរួមនៅក្នុងសវនាការ

---

[៤] *សូមមើលរឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Bagosora & ជនចំនួន ២៨ នាក់ផ្សេងទៀត,* ICTR-98-37-A , សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញា ជំទាស់នឹងសេចក្ដីសម្រេចនៃការបញ្ជាក់របស់ចៅក្រមបដិសេធចោលការចោទប្រកាន់ទៅលើ Theonéste Bagosora និងជនចំនួន ២៨ នាក់ផ្សេងទៀត ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៣៤-៣៥៖ "មាត្រា ២៤ [លក្ខន្តិកៈរបស់តុលាការ ICTR] ចែងថា ដោយយល់ថា អង្គជំនុំជម្រះឧទ្ធរណ៍ អាចស្ដាប់បណ្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចនានារបស់សាលាដំបូងចេញពី "បុគ្គលមួយចំនួន ដែលត្រូវបានចោទប្រកាន់ដោយសាលាដំបូង ឬចេញពីរដ្ឋអាជ្ញា" *simpliciter* ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ការបកស្រាយមាត្រា ២៤ ដែលអាចនឹងផ្ដល់ឲ្យរដ្ឋអាជ្ញានូវសិទ្ធិក្នុងការប្ដឹងសាទុក្ខដោយគ្មានកម្រិត នៅខណៈដែលសិទ្ធិក្នុងការដាក់បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ ត្រូវបានកម្រិតនោះ អាចនឹងរំលោភបំពានគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីគ្នា។ ជាក់ស្ដែង គោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្ដីគ្នា តម្រូវឲ្យបណ្ដាភាគី មានសិទ្ធិក្នុងការឆ្លើយតបតាមរយៈការដាក់បណ្ដឹងឧទ្ធរណ៍... ស្របជាមួយគោលការណ៍នេះ សាលាឧទ្ធរណ៍យល់ឃើញថា ចំពោះសំណុំរឿងនេះ ក្នុងករណីដែលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ រដ្ឋអាជ្ញាមិនអាចមានសិទ្ធិអំណាចច្រើនជាងក្នុងការដាក់បណ្ដឹងសាទុក្ខច្រើនជាងជនជាប់ចោទទាំងនោះទេ"។

ដែលមានរយៈពេលយូរនោះទេ ប្រសិនបើ អ.វ.ត.ក គ្មានយុត្តាធិការមកលើរូបគាត់ទេនោះ[៥]។

១១. ប្រសិនបើមានមន្ទិលសង្ស័យណាមួយចំពោះការបកស្រាយវិធាន ១០៤(៤)(ក) វិធាន ២១(១) ខាងលើ ក៏ដូចជាគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ជនជាប់ចោទ (in dubio pro reo)*[៦] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនោះ នោះចាំបាច់តម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូល

---

[៥] ដូចអ្វីដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") បានពន្យល់រួចមកហើយ នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ *Tadic*៖ "បញ្ហាជាសារវ័ន្ត តួយ៉ាងដូចជាបញ្ហាយុត្តាធិការរបស់តុលាការអន្តរជាតិ មិនត្រូវទុករង់ចាំដល់មានសេចក្ដីសម្រេច នៅចុងបញ្ចប់នៃការជំនុំជម្រះក្ដីដែលអាចមានរយៈពេលវែង មានការរំជួលចិត្ត និងដែលចំណាយលុយច្រើននោះទេ... តើមានផលប្រយោជន៍យុត្តិធម៌មានកម្រិតខ្ពស់ទេ ប្រសិនបើសេចក្ដីសម្រេចមួយផ្ដល់ជាប្រយោជន៍ដល់ជនជាប់ចោទទៅវិញ បន្ទាប់ពីជនជាប់ចោទនេះបានឆ្លងកាត់អ្វីដែលហៅថាជាការជំនុំជម្រះក្ដីដែលមិនចាំបាច់នោះ។ នៅតុលាការសុភវិនិច្ឆ័យគួរតែត្រូវបានឱ្យតម្លៃ មិនមែនត្រឹមតែនៅពេលដែលអង្គហេតុទាំងឡាយត្រូវបានវាយតម្លៃនោះទេ ប៉ុន្តែសុភវិនិច្ឆ័យគួរតែត្រូវបានឱ្យតម្លៃដោយស្មើគ្នា នៅពេលដែលច្បាប់ត្រូវបានវិភាគ ហើយវិធានសមរម្យត្រូវជ្រើសរើសយកមកប្រើនោះ"។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Tadic,* IT-94-1-AR72, សាលដីកាលើពាក្យសុំប្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់មេធាវីការពារក្ដី ចំពោះយុត្តាធិការ ចុះថ្ងៃទី ២ ខែ តុលា ឆ្នាំ ១៩៩៥ ("សាលដីកាបណ្ដឹងឧទ្ធរណ៍រឿងក្ដី *Tadic*") កថាខណ្ឌ ៦។

[៦] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងលើផ្នែកដែលពាក់ព័ន្ធថា ៖ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អនុវត្តចំពោះការយល់ឃើញលើអង្គច្បាប់ ទៅតាមការបកស្រាយវិធានច្បាប់ស៊ីវិល។ កថាខណ្ឌ ៣១ នៃសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្ដីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E50/3/1/4 ចែងថា៖ "ដោយគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះសម្រាប់តែភាពមន្ទិលសង្ស័យដែលនៅតែមាន ក្រោយពីមានការបកស្រាយរួច។ ហេតុដូច្នេះ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែអនុវត្តជាសំខាន់ចំពោះភាពមន្ទិលសង្ស័យអំពីខ្លឹមសារនៃនិយាមគតិយុត្ត ដែលនៅតែមានក្រោយការអនុវត្តវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការពិចារណាលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ទីកន្លែងក្នុងប្រព័ន្ធ រួមទាំងការជាប់ទាក់ទិនទៅនឹងគោលការណ៍សំខាន់ៗជាមូលដ្ឋាន និងគោលបំណងនៃគោលការណ៍នេះ"។ មាត្រា ២២(២) នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("លក្ខន្តិកៈ តុលាការ ICC") ប្រភពឯកសារសំអាងផ្នែកច្បាប់របស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បញ្ជាក់ពីការអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ចំពោះការយល់ឃើញផ្នែកច្បាប់ថា៖ "ចំពោះករណីដែលមានន័យមិនប្រាកដ [ចំពោះនិយមន័យរបស់បទឧក្រិដ្ឋ] និយមន័យ គួរត្រូវបានបកស្រាយជាប្រយោជន៍ដល់បុគ្គលដែលកំពុងស្ថិតក្នុងការស៊ើបអង្កេត រងការចោទប្រកាន់ ឬត្រូវបានផ្ដន្ទាទោស"។ ទោះបីជាលក្ខន្តិកៈរបស់តុលាការ ICC គឺជាច្បាប់ដែលផ្អែក

ធ្វើការបកស្រាយវិធាន ១០៤(៤)(ក) ដើម្បីការពារដល់ប្រយោជន៍របស់លោក អៀង សារី[៧]។

## ខ. សំណើសុំឱ្យមានសវនាការជាសាធារណៈ

១២. មេធាវីការពាក្តីស្នើឱ្យមានសវនាការជាសាធារណៈដើម្បីលើកយកបញ្ហានានានៅក្នុងបណ្តឹងសាទុក្ខមកដោះស្រាយ។ វិធាន ១០៩(១) បង្ហាញថា សវនាការលើបណ្តឹងសាទុក្ខ ជាទូទៅត្រូវប្រព្រឹត្តទៅជាសាធារណៈ[៨]។ បណ្តឹងសាទុក្ខនេះប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះមួយប្រកបដោយយុត្តិធម៌ ព្រមទាំងប៉ះពាល់ដល់កិច្ចដំណើរការរបស់នីតិវិធីនាពេលអនាគត។ វាគឺជាចំណាប់អារម្មណ៍ចំពោះសាធារណជនកម្ពុជា។ គ្មានបញ្ហាណាមួយក្នុងចំណោមបញ្ហាដែលត្រូវបានលើកឡើងនេះ ជាបញ្ហាសម្ងាត់នោះទេ។

# IV. ច្បាប់ជាធរមាន

## ក. គោលការណ៍*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*

---

លើសន្ធិសញ្ញា មិនមែនជាច្បាប់ទំនៀមទម្លាប់ក៏ដោយ ក៏មាត្រា ២២ បញ្ជាក់ពីការទទួលស្គាល់ និងទទួលយកគោលការណ៍នីត្យានុកូលភាព និងគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទដែរ។

[៧] អង្គបុរេជំនុំជម្រះ បានសម្រេចកាលពីពេលមុនថា វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវថាអង្គជំនុំជម្រះ ត្រូវ "បកស្រាយឱ្យបានទូលំទូលាយ នូវសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌ ត្រូវបានគាំពារក្នុងកាលៈទេសៈនេះ..."។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D390/1/2/4 កថាខណ្ឌ ១៣។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារលេខ A190/I/20 កថាខណ្ឌ ៣៦; សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំអនុញ្ញាតថតសម្លេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ឯកសារលេខ A371/2/12 កថាខណ្ឌ ១៣-១៤។

[៨] វិធាន ១០៩(១) ចែងថា៖ "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូល ត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូល អាចធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

១៣. មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា បណ្តឹងអាជ្ញាត្រូវផុតរលត់ នៅពេលអាជ្ញាអស់ជំនុំ *(res judicata)*។ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា៖ "ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេ ចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ"។ មាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលជាច្បាប់មួយមានអនុភាពនៅ អ.វ.ត.ក[៩] តម្រូវថា៖ "គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ"។

### ខ. ការលើកលែងទោស និងការអនុគ្រោះ

១៤. រដ្ឋធម្មនុញ្ញចែងថា ព្រះមហាក្សត្រ និង/ឬ សភាជាតិ មានសិទ្ធិក្នុងការផ្តល់ការអនុគ្រោះទោសដោយគ្មានកំហិត[១០]។ អ.វ.ត.ក មានសមត្ថកិច្ចយ៉ាងច្បាស់អាចកំណត់ពីវិសាលភាពនៃព្រះរាជក្រឹត្យលើកលែងទោសតែប៉ុណ្ណោះ[១១]។

## V. ឧទ្ធរណ៍

### ក. អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រលំ ដោយខកខានមិនបានយកព្រះរាជក្រឹត្យលើកលែងទោស និងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មកអនុវត្តដើម្បីរារាំងការចោទប្រកាន់ទៅលោក អៀង សារី នាពេលបច្ចុប្បន្ននេះ។

---

[៩] រដ្ឋធម្មនុញ្ញ មាត្រា ៣១; កិច្ចព្រមព្រៀង មាត្រា ១២(២); ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា៣៣ថ្មី។

[១០] រដ្ឋធម្មនុញ្ញ មាត្រា ២៧ចែងថា៖ "ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិ បន្ធូរបន្ថយទោស និងលើកលែងទោស"។ មាត្រា ៩០ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា៖ "រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ"។

[១១] មាត្រា៤០ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងនៅក្នុងផ្នែកដែលជាប់ពាក់ព័ន្ធថា៖ "វិសាលភាពនៃការលើកលែងទោស ឬអនុគ្រោះទោស អាចបានផ្តល់ឲ្យ នៅមុនពេលច្បាប់នេះចូលជាធរមាន នឹងជាបញ្ហាដែលនឹងត្រូវ សម្រេចដោយអង្គជំនុំជម្រះ"។

១៥. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ដោយសារតែការខ្វះចន្លោះនៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការនៅឆ្នាំ១៩៧៩ សេចក្តីសម្រេចរបស់តុលាការនាពេលនោះ មិនអាចជាសេចក្តីសម្រេចដែលមានសុពលភាព និងមិនអាចយកមកធ្វើជាកម្មវត្ថុសម្រាប់ការលើកលែងទោស ឬសម្រាប់ការអនុវត្តគោលការណ៍ *អាជ្ញាអស់ជំនុំ* ដែលមានចែងនៅក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ[១២]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុវត្តចំពោះតែកិច្ចដំណើរការនីតិវិធីនៅក្នុងរបបគតិយុត្តិថ្នាក់ជាតិតែប៉ុណ្ណោះ មិនអាចយកទៅអនុវត្តចំពោះកិច្ចដំណើការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក បានឡើយ[១៣]។ អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រលំនៅលើអង្គច្បាប់ ព្រមទាំងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន៖ **១.** អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការកំណត់ថា សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលគ្មានសុពលភាពដែលបណ្តាលឲ្យមានការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានកំណត់យ៉ាងមានប្រសិទ្ធភាពផ្លូវការថាព្រះរាជក្រឹត្យលើកលែងទោសមិនមានសុពលភាព។ **២.** ទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចកំណត់ពីសុពលភាពរបស់សាលក្រមឆ្នាំ១៩៧៩ ក៏អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយយល់ឃើញថា សាលក្រមនេះគ្មានសុពលភាព។ **៣.** អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ ចំពោះការសម្រេចថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនអាចយកមកអនុវត្តបាននៅ អ.វ.ត.ក។ **៤.** អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ព្រមទាំងបានរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានយកព្រះរាជក្រឹត្យលើកលែងទោស មកអនុវត្តដើម្បីរាំងការចោទប្រកាន់ទៅលើលោក អៀង សារី នៅចំពោះមុខ អ.វ.ត.ក និង **៥.** អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ព្រមទាំងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបានយកគោលការណ៍ *អាជ្ញាអស់ជំនុំ* និងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មកអនុវត្ត ដើម្បីរាំងការ

---

[១២] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣០។

[១៣] *ដូចឯកសារយោងមុន* កថាខណ្ឌ ៣២។

ចោទប្រកាន់ ទៅលើលោក អៀង សារី នៅចំពោះមុខ អ.វ.ត.ក ឡើយ។

**១. អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយបានសម្រេចថា សាលក្រម ឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចរបស់តុលាការដែលគ្មានប្រសិទ្ធភាព ដែលបណ្តាលឱ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការកំណត់ដោយប្រសិទ្ធភាពថា ព្រះរាជក្រឹត្យលើកលែងទោសមិនមានសុពលភាព**

១៦. អង្គជំនុំជម្រះសាលាដំបូងមិនមានសមត្ថកិច្ចក្នុងការសម្រេចថា សាលក្រម ឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចរបស់តុលាការមួយដែលមិន "ត្រឹមត្រូវស្របច្បាប់"[១៤] នោះទេ។ យុត្តាធិការរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[១៥] គឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គ្មានផ្នែកណាមួយនៅក្នុងកិច្ចព្រមព្រៀង ឬច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានផ្តល់យុត្តាធិការឱ្យអង្គជំនុំជម្រះសាលាដំបូង ក្នុងការត្រួតពិនិត្យមើលសេចក្តីសម្រេច និងសាលក្រមនានារបស់តុលាការជាតិកម្ពុជាផ្សេងៗទៀតទេ[១៦]។ អង្គជំនុំជម្រះសាលាដំបូងផ្ទាល់ បានទទួលស្គាល់ថា

---

[១៤] *ដូចឯកសារយោងមុន* កថាខណ្ឌ ៣០។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលលើកឡើងថា សាលក្រម ឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចរបស់តុលាការមួយដែលគ្មានសុពលភាព ខុសពីការយល់ឃើញរបស់អង្គបុរេជំនុំជម្រះចំពោះសាលក្រមឆ្នាំ១៩៧៩។ អង្គបុរេជំនុំជម្រះ មិនធ្លាប់បានសម្រេចថា សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចរបស់តុលាការមួយដែលគ្មានសុពលភាពនោះទេ។ អង្គបុរេជំនុំជម្រះគ្មានសមត្ថកិច្ចក្នុងការសម្រេចកិច្ចការនេះឡើយ។ អង្គបុរេជំនុំជម្រះគ្រាន់តែបានពិចារណា ថាតើ កង្វះខាតជាក់លាក់មួយចំនួន នៅក្នុងកិច្ចដំណើរការតុលាការនាឆ្នាំ១៩៧៩ នោះ អាចបង្កើតឱ្យមានការលើកលែងចំពោះការអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ឬយ៉ាងណានោះ ដោយហេតុថា គោលការណ៍នោះ មានចែងនៅក្នុងវិធាននីតិវិធី ក្នុងកម្រិតអន្តរជាតិ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ ១៣២-១៧៥។

[១៥] *សូមមើល* កិច្ចព្រមព្រៀង មាត្រា ១-២; ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កថាខណ្ឌ ២ថ្មី-៨។

[១៦] មាត្រា២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីរបៀបនៃការប្តឹងទៅតុលាការ។ គ្មានផ្នែកណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថាសាលាដំបូង (ដូចជា អង្គជំនុំជម្រះសាលាដំបូង នៃ អ.វ.ត.ក) អាចពិនិត្យមើលសាលក្រមរបស់តុលាការផ្សេងទៀតបានឡើយ។

អ.វ.ត.ក មាន "មន្ត្រីតុលាការបុគ្គលិកជាតិ និងអន្តរជាតិ ដែលមិនមានសមត្ថកិច្ចចូលរួម ឬធ្វើការវិនិច្ឆ័យ សេចក្តីសម្រេចដែលត្រូវធ្វើដោយតុលាការកម្ពុជាឡើយ... មិនមានការជាប់ទាក់ទងសមត្ថកិច្ច រវាង អ.វ.ត.ក និងតុលាការដទៃទៀត ដែលមាននៅក្នុងប្រព័ន្ធតុលាការកម្ពុជាទេ" [១៧]។

១៧. តាមរយៈការសម្រេចថា សាលក្រមឆ្នាំ១៩៧៩ មិនមែនជាសេចក្តីសម្រេចរបស់តុលាការ ដែលមានសុពលភាពមួយនោះ អង្គជំនុំជម្រះសាលាដំបូង បានធ្វើឱ្យព្រះរាជក្រឹត្យលើកលែងទោសគ្មានសុពលភាពយ៉ាងមានប្រសិទ្ធភាពរួចទៅហើយ។ ព្រះរាជក្រឹត្យលើកលែងទោសនេះ អាចត្រូវចាត់ទុកជាមោឃៈ នៅពេលការប្រទានការលើកលែងទោសនេះត្រូវបានផ្តល់ឱ្យ ប្រសិនបើការលើកលែងទោសនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីលើកលែងការផ្តន្ទាទោសមួយ ដែលមិនមានសុពលភាពនោះ។ អង្គជំនុំជម្រះសាលាដំបូងផ្ទាល់ក៏បានទទួលស្គាល់ថា ខ្លួនមិនមានសមត្ថកិច្ចក្នុងការសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យលើកលែងទោសទេ [១៨]។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានឆន្ទានុសិទ្ធិរបស់ខ្លួន តាមរយៈការប្រព្រឹត្តបែបនោះប្រកបដោយប្រសិទ្ធភាព។

**ខ. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចពីសុពលភាពរបស់សាលក្រមឆ្នាំ ១៩៧៩ ក៏ដោយ ក៏អង្គជំនុំជម្រះមានកំហុសលើផ្នែកអង្គច្បាប់ ចំពោះការយល់ឃើញថា សាលក្រមនោះជាសេចក្តីសម្រេចមួយដែលគ្មានសុពលភាព**

១៨. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចមួយ ដែលមិន "ត្រឹមត្រូវ អាចអនុវត្តបាន និងជាស្ថាពរ" [១៩] ប៉ុន្តែ ខកខានមិនពន្យល់នោះទេពីអត្ថន័យរបស់ឃ្លា

---

[១៧] *រឿងក្តី កាំង ហ្គេកអ៊ាវ* 001/18-07-2007/អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ ឱ្យនៅក្រៅឃុំ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារលេខ E39/5 កថាខណ្ឌ ១១-១២។

[១៨] អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា៖ "ខ្លួនពុំមានតួនាទីសម្រេចអំពីសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ និងសភាជាតិ ក៏ដូចជាសុពលភាពស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជក្រឹត្យឆ្នាំ១៩៩៦ឡើយ ដោយហេតុថា ការសម្រេចលើបញ្ហានេះជាបុព្វសិទ្ធិ របស់ក្រុមប្រឹក្សាធម្មនុញ្ញ"។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៩។

[១៩] *ដូចឯកសារយោងមុន* កថាខណ្ឌ ៣០។

ដែលលើកឡើងថា ជាសេចក្តីសម្រេចដែល "ត្រឹមត្រូវ" ឬ "ដែលអាចអនុវត្តបាន"[២០] នោះ។ សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចដែល "ត្រឹមត្រូវ" ក្នុងន័យមួយដោយសារសេចក្តីសម្រេចនោះជាសាលក្រមមួយពិតប្រាកដ ដែលសម្រេចដោយតុលាការប្រជាជនបដិវត្តន៍។ សាលក្រមនេះអាចអនុវត្តបាន ដោយមិនចាំបាច់គិតទេថាតើសាលក្រមនោះ ត្រូវបានអនុវត្តជាក់ស្តែងឬមួយយ៉ាងណានោះទេ។ ប្រសិនបើសាលក្រមនេះមិនមែនជាសេចក្តីសម្រេចដែលត្រឹមត្រូវ នោះរដ្ឋាភិបាលកម្ពុជាមិនចាំបាច់ធ្វើការចរចារពីព្រះរាជក្រឹត្យលើកលែងទោស ដែលជាប់ពាក់ព័ន្ធដោយផ្ទាល់យ៉ាងជាក់លាក់ ទៅនឹងសេចក្តីសម្រេចតុលាការនេះ ហើយព្រះមហាក្សត្រមិនចាំបាច់ផ្តល់ការលើកលែងទោសនោះទេ។

១៩. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា អង្គជំនុំជម្រះចាត់ទុកសាលក្រមឆ្នាំ១៩៧៩ ថាមិនមែនជាសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយហេតុថា "ច្បាប់កម្ពុជា ផ្តល់លទ្ធភាពឲ្យសាលក្រមនៃសវនាការ *កំបាំងមុខ* អាចប្តឹងទាស់បាន ហើយលោក អៀង សារី ពុំដែលបានបោះបង់ដោយផ្ទាល់ ឬដោយប្រយោលនូវសិទ្ធិជំទាស់ទៅនឹងសាលក្រមឆ្នាំ១៩៧៩ ម្តងណាឡើយ"[២១]។ ការដែលលោក អៀង សារី មិនបានដាក់សំណើសុំ ឬបោះបង់សិទ្ធិដែលគាត់អាចមានក្នុងការស្នើឲ្យមានការជំនុំជម្រះសារជាថ្មី មិនមែនជាមូលហេតុបណ្តាលឲ្យសាលក្រមរបស់គាត់ពុំមានភាពជាស្ថាពរ និងមិនអាចយកមកប្រើប្រាស់ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់គាត់នោះទេ។ សិទ្ធិក្នុងការដាក់សំណើឲ្យមានការជំនុំជម្រះសារជាថ្មី គឺក្នុងគោលបំណងដើម្បីការពារជនជាប់ចោទ។ នេះគឺជាសិទ្ធិផ្ទាល់ខ្លួន និងប្រកបដោយឆន្ទានុសិទ្ធិដែលជនជាប់ចោទអាចប្រើប្រាស់។ លោក Andre Klip និង លោក Harmen van der Wilt អ្នកប្រាជ្ញផ្នែកច្បាប់ជនជាតិហូល្លង់ បានធ្វើការវិភាគច្បាប់របស់ប្រទេសហូល្លង់ស្តីពី *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយពន្យល់ថា៖ "តាមទ្រឹស្តី ការពិនិត្យ... មិនត្រូវបានចាត់ទុកថាពាក់ព័ន្ធទៅនឹងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះទេ។ ការផ្តួចផ្តើមគឺស្ថិតនៅ

---

[២០] អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា ការរឹបអូសទ្រព្យសម្បត្តិ របស់ អៀង សារី ដែលជាការដាក់ទោស មិនត្រូវបានអនុវត្តទេ ដែលនេះអាចបង្កប់ន័យថា អង្គជំនុំជម្រះយល់ឃើញអត្ថន័យនៃពាក្យ "អាចអនុវត្តបាន" និងពាក្យ "ត្រូវបានអនុវត្ត" គឺដូចគ្នា។ *សូមមើលឯកសារយោងមុន* កំណត់សម្គាល់ជើងទំព័រ ៣។

[២១] *ដូចឯកសារយោងមុន* កថាខណ្ឌ ៣០។

លើជនដែលរងការផ្តន្ទាទោស ហើយស្ថានភាពរបស់ជននោះ អាចនឹងមិនឈានទៅរកសភាពកាន់តែធ្ងន់ធ្ងរនោះទេ ដោយសារការអនុវត្តនីតិវិធីនេះ"[២២]។

២០. លើសពីនេះទៀត ដោយសារការជំនុំជម្រះសារជាថ្មីមិនអាចប្រព្រឹត្តទៅបាននាពេលនោះ អង្គហេតុដែលលើកឡើងថា មិនមានការជំនុំជម្រះសារជាថ្មីនោះ មិនអាចយកមកប្រើប្រាស់ប្រឆាំងនឹងលោក អៀង សារី បានទេ។ យោងតាមក្រឹត្យច្បាប់ដែលបង្កើតតុលាការនេះ តុលាការប្រជាជនបដិវត្តន៍ គឺជា៖

> "តុលាការជំនុំជម្រះដោយបិទផ្លូវប្តឹងឧទ្ធរណ៍។ ជនដែលត្រូវកាត់ទោសប្រហារជីវិត មានសិទ្ធិស្នើសុំក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា អនុគ្រោះទោសឲ្យក្នុងកំណត់ ៧ថ្ងៃ គិតតាំងពីថ្ងៃកាត់សេចក្តី។ ក្នុងករណីអវត្តមានជនត្រូវកាត់ទោស កាលបរិច្ឆេទនេះ នឹងត្រូវ បានគិតចាប់ពីថ្ងៃដែលបិទផ្សាយសាលក្រមសម្រេចទោស នៅទីស្នាក់ការនៃគណៈកម្មាធិការប្រជាជនទីក្រុងភ្នំពេញ"[២៣]។

នាពេលនោះ មិនមានតុលាការឯទៀតដែលមានយុត្តាធិការអាចធ្វើការជំនុំជម្រះរឿងក្តីរបស់ លោក អៀង សារី សារជាថ្មីបានឡើយ។ ក្រឹត្យច្បាប់នេះបានបញ្ជាក់យ៉ាងច្បាស់ថា លោក អៀង សារី មិនអាចស្នើឲ្យតុលាការជាន់ខ្ពស់មួយ ធ្វើការពិនិត្យឡើងវិញចំពោះការផ្តន្ទាទោសរបស់ខ្លួននោះទេ ហើយនាពេលនេះ គាត់ក៏មិនអាចដាក់សំណើឲ្យពិនិត្យឡើងវិញនៅពេលនេះដែរ។ កិច្ចដំណើរការនីតិវិធីតុលាការ នៅ អ.វ.ត.ក នាពេលបច្ចុប្បន្ននេះ មិនមែនជា "ការជំនុំជម្រះសារជាថ្មី" នោះទេ។ លោក អៀង សារី កំពុងត្រូវបានជំនុំជម្រះដោយតុលាការកម្ពុជាមួយផ្សេង ក្រោមច្បាប់ដោយឡែក ទោះបីជាការជំនុំជម្រះទៅលើអំពើដដែល ដែលជាបទចោទនៅក្នុងឆ្នាំ ១៩៧៩ ក៏ដោយ។ ទោះបីជាអាចមានអំឡុងពេលដ៏ខ្លីមួយដែល លោក អៀង សារី អាចរកតុលាការមួយ ដើម្បីជំនុំជម្រះក្តីរបសគាត់សារជាថ្មីក៏ដោយ ក៏សាលក្រមឆ្នាំ១៩៧៩ ចាំបាច់ត្រូវតែចាត់ទុកជាសេចក្តីសម្រេចស្ថាពរដែរ។ លោក អៀង សារី មិនមានលទ្ធភាពក្នុងការជំនុំជម្រះសារជាថ្មីនោះទេ

---

[២២] Andre Klip & Harmen van der Wilt, *គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ របស់ប្រទេសហូល្លង់*, 73 REVUE INTERNATIONAL DE DROIT PENAL 1091, 1097 (2002) ("Klip & van der Wilt")។

[២៣] ក្រឹត្យច្បាប់លេខ១: ស្តីអំពីការបង្កើតតុលាការប្រជាជនបដិវត្តន៍នៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ របស់ពួក ប៉ុល ពត - អៀង សារី ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩។

ហើយគាត់ក៏មិនត្រូវបានទាមទារឲ្យដាក់សំណើសុំឲ្យមានការជំនុំជម្រះសារជាថ្មីមួយ ដើម្បីឲ្យសាលក្រមសម្រេចលើរឿងក្តីរបស់គាត់ អាចនឹងត្រូវគេចាត់ទុកជាសាលក្រមជាស្ថាពរដែរ។

### ៣. អង្គជំនុំជម្រះសាលាដំបូង មានកំហុសលើអង្គច្បាប់ ដោយបានសម្រេចថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនអាចយកមកអនុវត្តបាន នៅ អ.វ.ត.ក ទេ

២១. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុវត្តបានតែចំពោះកិច្ចដំណើរការនីតិវិធីតុលាការជាតិប៉ុណ្ណោះ មិនមែនអនុវត្តចំពោះ អ.វ.ត.ក "ដែលជាតុលាការអន្តរជាតុបនីយកម្មឡើយ"[២៤]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់លើបញ្ហាចំនួនបីគឺ៖ **ក.** ស្ថានភាពនាពេលបច្ចុប្បន្ននេះ គឺពាក់ព័ន្ធតែទៅនឹង "កិច្ចដំណើរការនីតិវិធីនៅក្នុងច្បាប់ជាតិ" តែប៉ុណ្ណោះ និងមិនជាប់ពាក់ព័ន្ធនឹងការអនុវត្តរបស់មាត្រា ១៤(៧)[២៥] ជាអន្តរជាតិនោះទេ។ **ខ.** ទោះបីជាស្ថានភាពនាពេលបច្ចុប្បន្នអាចនឹងចាត់ទុកថាជាបញ្ហានៃការអនុវត្តអន្តរប្រទេស ឬជាអន្តជាតិក្តី ក៏អង្គជំនុំជម្រះសាលាដំបូងមានកំហុសចំពោះការសម្រេចថា កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនអាចយកមកអនុវត្តបាននោះ និង **គ.** អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានពិចារណាវិធាននីតិវិធីនៅកម្រិតអន្តរជាតិ។ ប្រសិនបើវិធាននីតិវិធីបែបនេះត្រូវបានលើកយកមកពិចារណា នោះអង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយសារតែពិចារណាតែទៅលើវិធាននីតិវិធីនៅតុលាការ ICTY និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង ("IACtHR") តែប៉ុណ្ណោះ។

### ក. នេះមិនមែនជាបញ្ហានៃការអនុវត្តរវាងប្រទេស និងប្រទេស ឬជាអន្តរជាតិ នោះទេ

---

[២៤] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣២។

[២៥] អង្គបុរេជំនុំជម្រះ ដែលសំអាងហេតុរបស់ខ្លួនត្រូវបានគាំទ្រដោយអង្គជំនុំជម្រះសាលាដំបូងនោះ បានយោងការអនុវត្តកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងករណីនេះ ជាការអនុវត្តមួយដែលជាប់ពាក់ព័ន្ធក្នុងករណី "អន្តរប្រទេស"។ *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ ១២៨។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង មិនបានប្រើប្រាស់ ពាក្យ "អន្តរប្រទេស" នោះទេ។

២២. ការជំនុំជម្រះក្តីកាលពីពេលមុនរបស់លោក អៀង សារី នាឆ្នាំ១៩៧៩ ត្រូវបានប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា ដោយតុលាការកម្ពុជា។ ដូចគ្នានេះដែរ អ.វ.ត.ក គឺជាតុលាការមួយ "ដែលត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់"របស់កម្ពុជា[២៦]។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺអាចយកមកអនុវត្តជាច្បាប់នៅក្នុងប្រទេសកម្ពុជា និងជាពិសេស គឺនៅ អ.វ.ត.ក អនុលោមតាមរដ្ឋធម្មនុញ្ញ[២៧] កិច្ចព្រមព្រៀង[២៨] និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា[២៩]។

២៣. ទោះបីជា អ.វ.ត.ក អាចនឹងចាត់ទុកជា តុលាការ "អន្តរជាតុបនីយកម្ម"[៣០] ដោយយោងលើជំនួយផ្នែកបច្ចេកទេសអន្តរជាតិ ដែលតុលាការនេះបានទទួល និងរចនាសម្ព័ន្ធគ្នានពីររបស់តុលាការនេះក៏ដោយ ក៏នេះមិនបានបញ្ជាក់ថា អ.វ.ត.ក ជាតុលាការអន្តរជាតិនៃរដ្ឋមួយផ្សេងនោះទេ។ ចំពោះ អ.វ.ត.ក ទោះបីជាពាក្យ "អន្តរជាតុបនីយកម្ម" អាចនឹងចង្អុលបង្ហាញពីអ្វីក៏ដោយ ក៏តុលាការនេះមិនមែនជាតុលាការអន្តរជាតិ[៣១] នោះដែរ។ អ.វ.ត.ក ទទួលយុត្តាធិការ និងសមត្ថកិច្ចរបស់ខ្លួនតាមវិធីដូចគ្នាទៅនឹងតុលាការកម្ពុជាផ្សេងៗទៀតផងដែរ គឺតាមរយៈច្បាប់ជាតិរបស់កម្ពុជា។ ខុសពីតុលាការអន្តរជាតិឯទៀត អ.វ.ត.ក មិនស្ថិតនៅក្នុងទំនាក់ទំនង "តាមខ្សែទទឹង" ជាមួយនឹង

---

[២៦] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា២ថ្មី។

[២៧] រដ្ឋធម្មនុញ្ញ មាត្រា ៣១។

[២៨] កិច្ចព្រមព្រៀង មាត្រា ១២(២)។

[២៩] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ៣៣ថ្មី។

[៣០] *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣២។ សម្រាប់កិច្ចពិភាក្សាដ៏ស៊ីជម្រៅ ស្តីអំពីស្ថានភាពរបស់ អ.វ.ត.ក ក្នុងឋានៈជាតុលាការជាតិ និងពីអត្ថន័យរបស់ពាក្យ "អន្តរជាតុបនីយកម្ម"នោះ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ ឯកសារលេខ D427/1/6 កថាខណ្ឌ ៨-២០។

[៣១] ទោះបីជាកិច្ចព្រមព្រៀង ("លិខិតុបករណ៍ដ៏សំខាន់ចាំបាច់ និងក្នុងកម្រិត "ជាអន្តរជាតិ" ខ្លាំងបំផុត របស់ អ.វ.ត.ក") មានត្រឹមតែអំណាចផ្លូវច្បាប់ ដោយហេតុថា កិច្ចព្រមព្រៀងនេះ ត្រូវបានរួមបញ្ចូលទៅក្នុងច្បាប់ជាតិកម្ពុជា តែប៉ុណ្ណោះ-មិនមែនដោយសារតែ កិច្ចព្រមព្រៀងនេះ ត្រូវបានដាក់ឲ្យប្រើប្រាស់ដោយក្រុមប្រឹក្សាសន្តិសុខ (ដូចជាករណីរបស់សាលាក្តី *ពិសេស* មួយចំនួន) ឬមានអំណាចផ្លូវច្បាប់ដូចជាសន្ធិសញ្ញា (ដូចជាលក្ខន្តិកៈរបស់តុលាការ ICC)។

តុលាការកម្ពុជាដទៃទៀតនោះទេ[៣២] ទោះបីជាអង្គជំនុំជម្រះរបស់ អ.វ.ត.ក អាចនឹងត្រូវចាត់ទុកថា

---

[៣២] ពិចារណាលើទំនាក់ទំនងរបស់តុលាការ ICTY ជាមួយនឹងរដ្ឋផ្សេងទៀត ដែលត្រូវបានពន្យល់ដោយអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY នៅក្នុងរឿងក្តី Blaskic:

> យ៉ាងជាក់ច្បាស់ ក្រោមមាត្រា ១ នៃច្បាប់លក្ខន្តិកៈ តុលាការអន្តរជាតិ មានយុត្តាធិការរឿងក្តីព្រហ្មទណ្ឌតែលើរូបវន្តបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តនៅក្នុងទឹកដីអតីតយូហ្គោស្លាវី ចាប់តាំងពី (ថ្ងៃទី ១ ខែ មករា) ឆ្នាំ ១៩៩១។ តុលាការអន្តរជាតិ អាចធ្វើការចោទប្រកាន់ និងកាត់ទោសជនទាំងអស់នោះបាន។ នេះគឺជាយុត្តាធិការសំខាន់។ ទោះបីជាយ៉ាងណាក៏ដោយ វាច្បាស់ណាស់ថា សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ ដើម្បីនាំយកជនដែលរស់នៅក្រោមយុត្តាធិការរបស់អធិបតេយ្យ មកកាត់ទោស ដោយមិនផ្តល់ភ្នាក់ងារអនុវត្តផ្ទាល់ខ្លួន តុលាការអន្តរជាតិ ត្រូវផ្អែកលើកិច្ចសហការរបស់រដ្ឋនានា។ តុលាការអន្តរជាតិត្រូវងាកទៅរករដ្ឋនានា ប្រសិនបើចង់ធ្វើការស៊ើបអង្កេតបទល្មើស ប្រមូលភស្តុតាង កោះអញ្ជើញសាក្សី និងធ្វើការចាប់ខ្លួនជនដែលត្រូវបានចោទប្រកាន់ និងប្រគល់ឱ្យតុលាការអន្តរជាតិដោយប្រសិទ្ធភាព។ អ្នកធ្វើសេចក្តីព្រាងច្បាប់លក្ខន្តិកៈ បានធ្វើការពិចារណាចំណុចនេះតាមជាក់ស្តែង នៅក្នុងការកំណត់កាតព្វកិច្ចដល់គ្រប់រដ្ឋទាំងអស់ឱ្យជួយសហការ និងផ្តល់ជំនួយផ្លូវច្បាប់ដល់តុលាការអន្តរជាតិ។ កាតព្វកិច្ចនេះមានចែងនៅក្នុងមាត្រា ២៩ និងត្រូវបានចែងឡើងវិញនៅក្នុងកថាខណ្ឌ ៤ នៃសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ លេខ ៨២៧ (ឆ្នាំ ១៩៩៣)។ កម្លាំងចងភ្ជាប់កាតព្វកិច្ចនេះកើតចេញមកពីបទប្បញ្ញត្តិនៃជំពូក VII និងមាត្រា ២៥ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងពីសេចក្តីសម្រេចក្រុមប្រឹក្សាសន្តិសុខ ដែលត្រូវបានអនុម័តអនុលោមតាមបទប្បញ្ញត្តិទាំងអស់នោះ។ មូលដ្ឋានច្បាប់ពិសេសនៃមាត្រា ២៩ ពន្យល់ពីរឿងរ៉ាវថ្មីប្លែក និងអំណាចពិសេសតែមួយគត់ដែលបានផ្តល់ឱ្យតុលាការអន្តរជាតិ ក្នុងការចេញការបង្គាប់បញ្ជានានាដល់រដ្ឋអធិបតេយ្យនានា (ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាគោលការណ៍ រដ្ឋនានាមិនអាចត្រូវបាន "បង្គាប់បញ្ជា" ដោយរដ្ឋផ្សេងទៀត ឬដោយអង្គភាពអន្តរជាតិណាឡើយ)។ លើសពីនេះទៀត កាតព្វកិច្ចដែលបានកំណត់នៅក្នុងអត្ថន័យច្បាស់លាស់បំផុត នៅក្នុងមាត្រា ២៩ គឺជាកាតព្វកិច្ចដែលជាភារកិច្ច លើគ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ប្រៀបធៀបនឹងរាល់រដ្ឋជាសមាជិកផ្សេងទៀត។ ក្រុមប្រឹក្សាសន្តិសុខ ដែលជាអង្គភាពដែលរ៉ាប់រងការទទួលខុសត្រូវចម្បងសម្រាប់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ បានចូលរួមយ៉ាងខ្លាំងក្លាជាមួយគ្រប់រដ្ឋជាសមាជិកក្នុងការអនុវត្តតាមការបង្គាប់បញ្ជា និងសំណើរបស់តុលាការអន្តរជាតិ។ លក្ខណៈ និងខ្លឹមសារនៃកាតព្វកិច្ចនេះ ក៏ដូចជាប្រភពដែលវាកើតចេញមកធ្វើឱ្យច្បាស់លាស់ថា មាត្រា ២៩ មិនបង្កើតបាននូវទំនាក់ទំនងទ្វេភាគីនោះទេ។ មាត្រា ២៩ ដាក់កាតព្វកិច្ចលើរដ្ឋជាសមាជិកនានា ទៅលើសមាជិកទាំងអស់ផ្សេងទៀត ឬហៅម្យ៉ាងទៀតថា "កាតព្វកិច្ចដែលអនុវត្តចំពោះគ្រប់រដ្ឋ *erga omnes partes*"។ តាមរយៈភស្តុតាងដូចគ្នា មាត្រា ២៩ អះអាងពីផលប្រយោជន៍សហគមន៍នៅក្នុងការប្រតិបត្តិមាត្រានេះ។ និយាយម្យ៉ាងទៀត គ្រប់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិមានផលប្រយោជន៍ផ្លូវច្បាប់នៅក្នុងការបំពេញកាតព្វកិច្ចដែលបានកំណត់នៅក្នុងមាត្រា ២៩..."

ជា “អង្គជំនុំជម្រះវិសាមញ្ញ” ដោយមានលក្ខណៈខុសប្លែកមួយចំនួនពីតុលាការកម្ពុជាផ្សេងទៀតក៏ដោយ។ ដូច្នេះ មិនមានការអនុវត្តជាអន្តរជាតិនៃគោលការណ៍ស្តីពី *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*ពាក់ព័ន្ធនោះទេ។ អ.វ.ត.ក មិនត្រូវបានស្នើសុំឱ្យទទួលស្គាល់សាលក្រមបរទេសនោះទេ តែត្រូវបានស្នើសុំឱ្យទទួលស្គាល់សាលក្រមរបស់តុលាការកម្ពុជា។ ដូចលោក Klip និងលោក van der Wilt បានពន្យល់រួចមកហើយថា៖ “ប្រសិនបើទស្សនទាន “រដ្ឋ” បាត់បង់អត្ថន័យរបស់វានោះ វាមិនគួរធ្វើឱ្យមានការការពារបុគ្គលកាន់តែតិចទៅនោះទេ”[៣៣]។

**ខ. ទោះបីជាមានបញ្ហាជាប់ពាក់ព័ន្ធទៅនឹងការអនុវត្តអន្តរប្រទេស ឬជាអន្តរជាតិក៏ដោយ ក៏កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចអនុវត្តបាន**

២៤. ទោះបីជា អ.វ.ត.ក អាចត្រូវចាត់ទុកថាជាតុលាការអន្តរជាតិក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង ដោយបានសម្រេចថា កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមិនអាចយកមកអនុវត្តបាននៅក្នុងស្ថានភាពបែបនេះ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនបានប្រើប្រាស់ពាក្យពេចន៍ ដែលកម្រិតវិសាលភាពកតិកាសញ្ញាអន្តរជាតិនេះចំពោះតែកិច្ចដំណើរការនីតិវិធីតុលាការថ្នាក់ជាតិនោះទេ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ អាចគ្មានអំណាចច្បាប់នៅក្នុងស្ថានប័នអន្តរជាតិមួយចំនួន ដែលអង្គជំនុំជម្រះសាលាដំបូង បានយកមកពិចារណា ប៉ុន្តែ កតិកាសញ្ញាអន្តរជាតិនេះ មានអនុភាពផ្នែកច្បាប់នៅកម្ពុជា និងជាពិសេស នៅ អ.វ.ត.ក ហើយចាំបាច់ត្រូវតែយកមកអនុវត្ត។

២៥. សាលាក្តីពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត សាលាក្តី “កូនកាត់” បានយល់ឃើញថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អាចយកមកអនុវត្តបាននៅប្រទេសទីម័រខាងកើត ដោយយោងទៅបទបញ្ជា UNTAET ដែលបង្កើតឱ្យមានសាលាក្តីពិសេស និងដោយសារមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង

---

រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blaskic* IT-95-14-AR108*ស្ទួន* សាលក្រម លើសំណើសុំរបស់សាធារណៈរដ្ឋក្រូអាតសុំពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូង II ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៧ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ២៦។ *សូមមើលផង ដែរ* កថាខណ្ឌ ២៧ ដល់ ៣១។

[៣៣] Klip & van der Wilt ត្រង់ទំព័រ ១១៣៥។

សិទ្ធិនយោបាយដែលមានអនុភាពផ្នែកច្បាប់នៅក្នុងប្រទេសទីម័រខាងកើត[៣៤]។ ស្រដៀងគ្នានេះដែរ កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏មានអំណាចច្បាប់នៅកម្ពុជា និងនៅ អ.វ.ត.ក ដែរ។

២៦. ប្រទេសហូល្លង់មានមន្ទិលចំពោះមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដោយហេតុថា "រដ្ឋាភិបាលប្រទេសហូល្លង់នៅមានមន្ទិលថាតើមាត្រា១៤ កថាខណ្ឌ ៧ អាចត្រឹមតែគ្រប់ដណ្តប់ទៅលើការអនុវត្តថ្នាក់ជាតិ ឬការអនុវត្តថ្នាក់អន្តរជាតិ ចំពោះគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែរឬយ៉ាងណានោះ។ ចំពោះករណីដែលអនុវត្តក្នុងកម្រិតអន្តរជាតិ តុលាការប្រទេហូល្លង់អាចនឹងត្រូវមានកាតព្វកិច្ច ឲ្យបន្ថយទោស ដែលនឹងត្រូវផ្តន្ទាទោសនៅឯបរទេស ចំពោះករណីដែលការផ្តន្ទាទោស នៅមិនទាន់បាន អនុវត្តឲ្យបានពេញលេញ ដែលលក្ខខណ្ឌតម្រូវមួយ [ច្បាប់ព្រហ្មទណ្ឌហូល្លង់] មិនបានចែង"[៣៥]។ សមាគមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[៣៦] បានអនុម័តសេចក្តីសម្រេចដោយបានលើកឡើងថា៖ "គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គួរចាត់ទុកជាសិទ្ធិមនុស្ស ដែល

---

[៣៤] រឿងក្តី *អគ្គរដ្ឋអាជ្ញារងទទួលបន្ទុកឧក្រិដ្ឋកម្មធ្ងន់ធ្ងរ តទល់នឹង Wiranto និងជនឯទៀត.*, រឿងក្តីលេខ 05/2003, សេចក្តីសម្រេចគតិយុត្តិ ពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ Ne Bis In Idem* នាដំណាក់កាលចេញដីកាចាប់ខ្លួន នៃកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៥-១៧។ សេចក្តីសម្រេច ត្រូវបានកំណត់ថា គោលការណ៍នេះ មិនបានរារាំងការចោទប្រកាន់ នៅចំពោះមុខសាលាក្តីពិសេស ទៅលើជនជាប់ចោទ ដែលត្រូវបានចាប់ខ្លួននៅក្នុងប្រទេសឥណ្ឌូនេស៊ី - មិនមែនដោយសារគោលការណ៍នោះ មិនមានការអនុវត្តអន្តរប្រទេសនោះទេ គឺដោយសារតែមានការយល់ឃើញថា គោលការណ៍នោះ មិនអាចយកមកអនុវត្តបាន នាដំណាក់កាលចេញដីកាចាប់ខ្លួន នៃកិច្ចដំណើរការនីតិវិធី។ *ដូចឯកសារយោងមុន* កថាខណ្ឌ ១៨-៣៤។

[៣៥] Klip & van der Wilt ត្រង់ទំព័រ ១១០១។

[៣៦] សមាគមន៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបង្កើតឡើងនៅទីក្រុងប៉ារីស នាឆ្នាំ១៩២៤។ សមាគមន៍នេះ ជាអ្នកបន្តវេន សហព័ន្ធច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានបង្កើតឡើងនាឆ្នាំ ១៨៨៩ នៅទីក្រុងវៀនណា។ សមាគមន៍នេះ គឺជាសមាគមន៍អ្នកជំនាញច្បាប់ព្រហ្មទណ្ឌ ដែលចំណាស់ជាងគេ និងជាសមាគមន៍មួយក្នុងចំណោមសមាគមន៍វិទ្យាសាស្ត្រ ដែលមានវ័យចំណាស់ជាច្រើននៅក្នុងពិភពលោក។ *សូមមើល* គេហទំព័រសមាគមន៍ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ *អាចអានបាន នៅ៖* http://www.penal.org/?page=mainaidp&id_rubrique=13&lang=fr។

អាចយកមកអនុវត្តផងដែរ នៅក្នុងករណីអន្តរប្រទេស ឬក្នុងកម្រិតអន្តរជាតិ”[៣៧]។ ឧទាហរណ៍ទាំងនេះបង្ហាញថា ទោះបីជា អ.វ.ត.ក ត្រូវបានចាត់ទុកថាជាតុលាការ “អន្តរជាតុបនីយកម្ម” និងស្ថិតនៅក្នុងរចនាសម្ព័ន្ធខ្មែរទទឹង ចំពោះតុលាការប្រជាជនបដិវត្តន៍ក៏ដោយ ក៏កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អាចយកមកអនុវត្តបានដែរ។

**គ. វិធានស្តីពីនីតិវិធីត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ មិនគួរត្រូវបានលើកយកមកពិចារណានោះទេ ប្រសិនបើវិធានស្តីពីនីតិវិធីត្រូវបានលើកយកមកពិចារណានោះមិនត្រូវកម្រិតវិធានស្តីពីនីតិវិធីទាំងនេះ ត្រឹមតែវិធានស្តីពីនីតិវិធីនៅតុលាការ ICTY និងតុលាការ IACtHR នោះទេ**

២៧. អនុលោមតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ប្រសិនបើច្បាប់កម្ពុជា និងនីតិវិធីដែលមានជាធរមាន “ពុំបានចែងពីករណីពិសេសមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ”[៣៨]។ ទោះបីជាអង្គជំនុំជម្រះមិនបានលើកឡើងឲ្យបានច្បាស់ក៏ដោយ អង្គជំនុំជម្រះសាលាដំបូងទំនងជាពិចារណាគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដូចអ្វីដែលជាការបកស្រាយរបស់តុលាការ ICTY និងតុលាការ IACtHR ដោយសារអង្គជំនុំជម្រះយល់ឃើញថា មានភាពមិនច្បាស់លាស់ពាក់ព័ន្ធទៅនឹងការបកស្រាយ ឬការអនុវត្តមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅ អ.វ.ត.ក។ អង្គជំនុំជម្រះសាលាដំបូងមិនទំនងជាអនុវត្តតាមវិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះនោះទេ ដែលជាដំបូងបានធ្វើការពិចារណាទៅលើការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ បន្ទាប់មកពិចារណាទៅលើការអនុវត្តកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅមុនពេលធ្វើការសម្រេចជាចុងក្រោយថាតើវិធានស្តីពីនីតិវិធីដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ អាចនឹងតម្រូវឲ្យមានការអនុវត្តគោលការណ៍នេះឲ្យបានទូលំទូលាយ

---

[៣៧] សេចក្តីសម្រេច ផ្នែក IV B.4 ត្រូវបានអនុម័តដោយ សមាជអន្តរជាតិ ស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លើកទី XVIth, *អាចអានបាននៅគេហទំព័រ៖* http://www.penal.org/IMG/pdf/NEP21anglais.pdf។

[៣៨] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា ៣៣ថ្មី។

ឬមួយយ៉ាងណានោះ[៣៩]។

២៨. វិធានស្តីពីនីតិវិធី ដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ មិនត្រូវយកមកពិចារណាទៅលើស្ថានភាពនាពេលបច្ចុប្បន្ននេះទេ ដោយហេតុថា ទាំងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បញ្ជាក់ថា មាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺត្រូវយកមកអនុវត្តនៅ អ.វ.ត.ក។ ពាក្យពេចន៍របស់មាត្រា ១៤(៧) បញ្ជាក់បានច្បាស់ណាស់។ មាត្រានេះរារាំងមិនឱ្យមានការចោទប្រកាន់ចំពោះករណីដែលជនជាប់ចោទ ត្រូវបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។ មិនមានភាពមិនច្បាស់លាស់ទៅលើការអនុវត្តមាត្រា ១៤(៧) ឬ ទៅលើការបកស្រាយលើមាត្រានេះនោះទេ។ ដោយហេតុថាកតិកាសញ្ញានេះ ជាកតិកាសញ្ញាមានការទទួលស្គាល់យ៉ាងទូលំទូលាយជាអន្តរជាតិ មិនមានបញ្ហាចោទពាក់ព័ន្ធទៅនឹងភាពស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិនោះទេ។ ដូច្នេះ វិធានស្តីពីនីតិវិធីអន្តរជាតិ គឺមិនអាចអនុវត្តបានទេ ហើយមិនត្រូវយកមកពិចារណា ឬឱ្យតម្លៃលើសពីច្បាប់ដែលមានជាធរមាននោះទេ។

២៩. ទោះបីជាវិធានស្តីពីនីតិវិធីដែលត្រូវបានបង្កើតនៅកម្រិតអន្តរជាតិ គួរត្រូវលើកយកមកពិចារណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងនៅក្នុងការវិភាគពីវិធានស្តីពីនីតិវិធីអន្តរជាតិរបស់ខ្លួន។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងគួរតែទទួលស្គាល់ថា ទោះបីជាសាលាក្តីអន្តរជាតិអាចមិនចងភ្ជាប់កាតព្វកិច្ចត្រូវអនុវត្តមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏ដោយ ក៏ អ.វ.ត.ក មានកាតព្វកិច្ចត្រូវគោរពតាមមាត្រានេះ ដោយយោងទៅរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[៤០]។ នីតិវិធីរបស់សាលាក្តីអន្តរជាតិ មិនអាចអនុម័តយ៉ាងសាមញ្ញ ដោយមិនបានពិចារណាទៅលើលក្ខណៈដោយឡែកនេះទេ។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយបានដាក់កំហិត

---

[៣៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ជំទាស់នឹងដីកាដំណោះស្រាយ កថាខណ្ឌ ១១៨-១៧៥។

[៤០] រដ្ឋធម្មនុញ្ញ មាត្រា ៣១; កិច្ចព្រមព្រៀង មាត្រា ១២; ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា មាត្រា ៣៣ថ្មី។

ការវិភាពរបស់ខ្លួនទៅលើវិធានស្តីពីនីតិវិធីអន្តរជាតិនៅចំពោះតុលាការ ICTY និងតុលាការ IACtHR។ អង្គជំនុំជម្រះសាលាដំបូងគួរតែបានយកមាត្រា ២០(៣)(ខ) នៃលក្ខន្តិកៈរបស់តុលាការ ICC មកពិចារណា ដោយមាត្រានេះអនុញ្ញាតឱ្យមានការជំនុំជម្រះសារជាថ្មី ចំពោះតែករណីដែលការជំនុំជម្រះកាលពីពេលមុនមិនត្រូវបានប្រព្រឹត្តទៅដោយឯករាជ្យ និងអនាគតិ *និង* "មិនស្របតាមចេតនានាំខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌"[៩១]។ ចំពោះករណីនាពេលបច្ចុប្បន្ននេះ គ្មានភស្តុតាង ឬគ្មានសូម្បីតែការចោទប្រកាន់ថា ការជំនុំជម្រះទោសនាឆ្នាំ១៩៧៩ មិនត្រូវបាន

---

[៩១] លក្ខន្តិកៈតុលាការ ICC មាត្រា ២០(៣)(ខ)។ នៅពេលពិចារណាវិធានស្តីពីនីតិវិធីនៅក្នុងកម្រិតអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូង គួរតែបានធ្វើការពិចារណាផងដែរទៅលើកិច្ចព្រមព្រៀង Schengen។ រដ្ឋជាសមាជិករបស់សហគមន៍អឺរ៉ុបជាក់លាក់មួយចំនួន គឺជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលហាមឃាត់ការចោទប្រកាន់ពីរដ្ឋសមាជិកមួយ ដោយមានករណីលើកលែងមួយចំនួន ប្រសិនបើមានការជំនុំជម្រះទោសរួចហើយ ចំពោះអំពើដែលពីរដ្ឋសមាជិកមួយទៀត។ *សូមមើល* អនុសញ្ញាដែលអនុវត្តកិច្ចព្រមព្រៀង Schengen ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៨៥ រវាងរដ្ឋាភិបាលនៃបណ្តារដ្ឋ នៃសហជីពសេដ្ឋកិច្ច Benelux សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋបារាំង ស្តីពីការលុបបំបាត់ចោលជាបណ្តើរៗ នៃការត្រួតពិនិត្យនៅព្រំប្រទល់រួមរបស់បណ្តារដ្ឋទាំងនោះ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩០ មាត្រា ៥៤-៥៨។ នៅអឺរ៉ុប៖

> សហប្រតិបត្តិការអន្តររដ្ឋបែបបុរាណនៅក្នុងបញ្ហាផ្នែកព្រហ្មទណ្ឌ ត្រូវបានដាក់ជំនួសដោយសហប្រតិបត្តិការតុលាការដែលត្រូវបានកែលម្អ ដោយផ្ទាល់រវាងតួអង្គនៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ។ លើសពីនេះទៀត បច្ចុប្បន្ននេះ តួអង្គទាំងនេះត្រូវតែទទួលស្គាល់នូវសេចក្តីសម្រេចរបស់តុលាការទៅវិញទៅមក ដោយផ្អែកទៅលើគោលការណ៍នៃការទទួលស្គាល់ទៅវិញទៅមក។ ជាលទ្ធផល បច្ចុប្បន្ននេះ ទិដ្ឋភាពដ៏សំខាន់នៃដំណើរការប្រព័ន្ធយុត្តិធម៌ ផ្នែកព្រហ្មទណ្ឌកំពុងតែកើតមាននៅក្នុងតំបន់អឺរ៉ុប ដោយពុំមានព្រំដែនកម្រិតខាងក្នុងឡើយ ដែលជាតំបន់តុលាការអន្តរប្រទេស។ តាមរយៈសេចក្តីសម្រេចលើក្របខណ្ឌគតិយុត្តិជាច្រើន គោលការណ៍នៃការទទួលស្គាល់ទៅវិញទៅមក ត្រូវបានបង្កើតឡើងសម្រាប់សេចក្តីសម្រេចរបស់តុលាការមុនពេលជំនុំជម្រះក្តី ដូចជា ការរឹបអូស ការប្រមូល ភស្តុតាង និងការចាប់ខ្លួន។ សេចក្តីសម្រេចរបស់តុលាការនៅក្នុងរដ្ឋសមាជិកមួយ មានអនុភាពគតិយុត្តិនៅក្នុងតំបន់ស្របច្បាប់របស់សហគមន៍អឺរ៉ុប។ សេចក្តីសម្រេចលើក្របខណ្ឌគតិយុត្តិដ៏ល្បីល្បាញបំផុត នៅក្នុងបរិបទនេះ គឺប្រាកដជាដីកាបង្គាប់ឱ្យនាំខ្លួនអឺរ៉ុប ដែលដាក់ជំនួសនីតិវិធីបត្យាប័នបែបបុរាណ។ ការទទួលស្គាល់ទៅវិញទៅមកនូវដីកាបង្គាប់ឱ្យនាំខ្លួនរបស់រដ្ឋនីមួយៗ មិនត្រឹមតែធ្វើឱ្យជនជាប់សង្ស័យប្រគល់ខ្លួនបានឆាប់រហ័សជាងមុនប៉ុណ្ណោះទេ នៅក្នុងសហគមន៍អឺរ៉ុប ប៉ុន្តែក៏បានធ្វើឱ្យគោលការណ៍ច្បាប់ ដូចជា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានយកមកអនុវត្តជាអន្តរប្រទេសផងដែរ។

John A.E. Vervaele, *The Transnational* Ne Bis in Idem *Principle in the EU Mutual Recognition and Equivalent Protection of Human Rights,* 1(2) UTRECHT L.REV. 100, 101 (2005).

ប្រព្រឹត្តទៅដោយចេតនានាំខ្លួនលោក អៀង សារី មកកាត់ទោសនោះទេ។ លក្ខន្តិកៈរបស់តុលាការ ICC ប្រាកដជាត្រូវបានជ្រើសយកជាការណែនាំជាងលក្ខន្តិកៈ និងករណីយុត្តិសាស្ត្ររបស់តុលាការ ICTY និងតុលាការ IACtHR។ លក្ខន្តិកៈរបស់តុលាការ ICC ជាសន្ធិសញ្ញាមួយដែលទទួលបានការចុះហត្ថលេខាដោយរដ្ឋដែលជាភាគីចំនួន ១១៥ រួមទាំងកម្ពុជាផងដែរ គឺជាតំណាងឲ្យនូវការឯកភាពជាឯកច្ឆន្ទជាអន្តរជាតិ លើសពីលក្ខន្តិកៈ និងយុត្តិសាស្ត្ររបស់តុលាការ ICTY និងតុលាការ IACtHR[៤២]។

## ៤. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ព្រមទាំងបានរំលោភបំពានអន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានយកព្រះរាជក្រឹត្យលើកលែងទោសមកអនុវត្ត

៣០. នៅប្រទេសកម្ពុជា លើកលែងទោសអាចនឹងត្រូវអនុវត្តចំពោះករណីការកាត់ទោស *ដោយកំបាំងមុខ*។ ឧទាហរណ៍ ព្រះអង្គម្ចាស់នរោត្តម សិរីវុឌ្ឍ ត្រូវបានកាត់ទោសដោយ *កំបាំងមុខ* នៅក្នុងឆ្នាំ១៩៩៦ ចំពោះការរៀបចំផែនការធ្វើឃាតនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ព្រះអង្គម្ចាស់ ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងរយៈពេលដប់ឆ្នាំ។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៨ ព្រះអង្គម្ចាស់បានទទួលការលើកលែងទោស។ នៅក្នុងឆ្នាំ១៩៩៩ ព្រះអង្គម្ចាស់បានវិលត្រលប់មកកាន់ប្រទេសកម្ពុជាវិញ និងទទួលបានការតែងតាំងជាឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីនៃក្រសួងមហាផ្ទៃទៀតផង[៤៣]។ នៅក្នុងខែមីនា ឆ្នាំ១៩៩៨ ព្រះអង្គម្ចាស់នរោត្តម សិរីវុឌ្ឍ ត្រូវបានកាត់ទោស *ដោយ*

---

[៤២] "លក្ខន្តិកៈរបស់តុលាការ ICC "បានធ្វើអន្តរតុលាបនីយកម្ម" គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌជាច្រើន ដែលត្រូវបានទទួលស្គាល់នៅក្នុងប្រព័ន្ធច្បាប់ជាតិ តាមរយៈការផ្តល់នូវអ្វីដែលទទួលបានការទទួលស្គាល់កាន់តែច្រើនឡើង ជាការចងក្រងច្បាប់ ឬការច្របាច់បញ្ចូលគ្នាជាព្រឹត្តិន័យនៃគោលការណ៍ទាំងនោះ ក្នុងកម្រិតអន្តរជាតិ។ លើសពីនេះទៀត មាតិការបស់លក្ខន្តិកៈរបស់តុលាការ ICC គឺជាការបញ្ចូលគ្នារវាងនីតិវិធីនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិជាសារធាតុ។ អង្គហេតុដែលមានរដ្ឋចំនួន ១២០ បានបោះឆ្នោតគាំទ្រលក្ខន្តិកៈនេះ នៅសន្និសិទនាទីក្រុងរ៉ូម ឆ្នាំ១៩៩៨ អាចនឹងនិយាយបានថា បានផ្តល់នូវភស្តុតាងយ៉ាងរឹងមាំ ស្តីពីការលេចឡើងនូវ *គោលការណ៍ដែលអំពើមួយក្លាយទៅជាវិធាននៃច្បាប់* ដោយយោងលើសភាព និងព្រំដែនរបស់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ DOMINIC MCGOLDRICK ET AL., THE PERMANENT INTERNATIONAL CRIMINAL COURT: LEGAL AND POLICY ISSUES 340, (Hart Publishing, 1st ed., 2004)។

[៤៣] *អត្ថបទរបស់សារព័ត៌មាន* ASIAN POLITICAL NEWS *មានចំណងជើងថា៖ King Sihanouk Says Amnesty for Exiles Depends on Hun Sen,* ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៨, *អាចអានបាននៅគេហទំព័រ៖*

*កំបាំងមុខ* ពីបទរួមគំនិតក្បត់ដើម្បីធ្វើរដ្ឋប្រហាររដ្ឋាភិបាល។ ព្រះអង្គម្ចាស់បានទទួលការលើកលែងទោស ហើយបានដឹកនាំគណបក្សហ្វ៊ុនស៊ិនប៉ិច ចូលរួមការបោះឆ្នោតជាតិនៅក្នុងឆ្នាំ ១៩៩៨ ព្រមទាំងទទួលការតែងតាំងជាប្រធានរដ្ឋសភា[៤៤] ទៀតផង។ ដូចគ្នានេះដែរនៅក្នុងខែមីនា ឆ្នាំ១៩៩៨ ឧត្តមសេនីយ៍ពីររូបរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច គឺឧត្តមសេនីយ៍ ញឹក ប៊ុនឆៃ និង ឧត្តមសេនីយ៍ សេរី កុសល ត្រូវបានកាត់ទោស *ដោយកំបាំងមុខ* ពីបទសមគំនិតធ្វើរដ្ឋប្រហាររដ្ឋាភិបាល។ ឧត្តមសេនីយ៍ទាំងពីររូប បានទទួលការលើកលែងទោសនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៨ ហើយលោក ញឹក ប៊ុនឆៃ បានទទួលការតែងតាំងជាសហរដ្ឋមន្ត្រីនៃក្រសួងការពារជាតិ[៤៥]។

---

http://www.thefreelibrary.com/_/print/PrintArticle.aspx?id+53002588; *អត្ថបទសារព័ត៌មាន* CNN WORLD *មានចំណងជើងថា៖ Coalition Agreement for Cambodia Comes with Royal Pardons,* ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ *អាចអានបាននៅគេហទំព័រ៖* http://articles.cnn.com/1998-11-13/world/9811_13_cambodia.01_1_coalition-government-pardons-new-coalition?_s=PM:WORLD; *អត្ថបទរបស់សារព័ត៌មាន* ASIAN POLITICAL NEWS *មានចំណងជើងថា៖ King Sihanouk"s Half-Brother Returns Home,* ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៩ *អាចអានបាននៅគេហទំព័រ៖* http://www.thefreelibrary.com/_/print/PrintArticle.aspx?id=53642360; *អត្ថបទរបស់សារព័ត៌មាន* TAIPEI TIMES *មានចំណងជើងថា៖ Cambodia's PM Fires Two Officials in Cabinet Reshuffle*, ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ *អាចអានបាននៅគេហ ទំព័រ៖* http://www.taipeitimes.com/News/world/archives/2006/03/22/2003298602។

៤៤ *អត្ថបទរបស់សារព័ត៌មាន* NEW YORK TIMES *មានចំណងជើងថា៖ Cambodian Court Convicts Ousted Premier,* ចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៨ *អាចអានបាននៅគេហទំព័រ៖* http://www.nytimes.com/1998/03/05/world/cambodian-court-convicts-ousted-premier.html?ref=norodomranariddh; *អត្ថបទរបស់សារព័ត៌មាន* NEW YORK TIMES *មានចំណងជើងថា៖ Pardon Issued as a Step to Cambodian Elections*, ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៨ *អាចអានបាននៅគេហទំព័រ៖* http://www.nytimes.com/1998/03/22/world/world-news-briefs-pardon-issued-as-a-step-to-cambodian-elections.html?ref=norodomranariddh; *អត្ថបទរបស់សារព័ត៌មាន* NEW YORK TIMES *មានចំណងជើងថា៖ Cambodian Emerges as Sole Prime Minister*, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ *អាចអានបាននៅគេហទំព័រ៖* http://www.nytimes.com/1998/11/14/us/cambodian-emerges-as-sole-prime-minister.html?ref=norodomranariddh។

៤៥ *អត្ថបទរបស់សារព័ត៌មាន* ASIAN POLITICAL NEWS *មានចំណងជើងថា៖ King Sihanouk Says Amnesty for Exiles Depends on Hun Sen,* ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៨, *អាចអានបាននៅគេហទំព័រ៖*

នៅក្នុងខែធ្នូ ឆ្នាំ២០០៥ សម រង្ស៊ី ត្រូវបានកាត់ទោស *ដោយកំបាំងមុខ* ពីបទបរិហារកេរ្តិ៍។ គាត់បានទទួលការលើកលែងទោសនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៦[៤៦]។ ដើម្បីយល់ឃើញឲ្យដូចគ្នាទៅនឹងអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការលើកលែងទោសអាចនឹងមិនផ្ដល់ឲ្យដោយផ្អែកលើសាលក្រម ដែលជាសេចក្ដីសម្រេចនៅក្នុងសវនាការប្រព្រឹត្តទៅ *ដោយកំបាំងមុខ* ដោយហេតុថា សវនាការទាំងនេះ មិនមែនជាការជំនុំជម្រះជាស្ថាពរ នោះមានន័យថា ការលើកលែងទោសទាំងប៉ុន្មានដូចបានលើកឡើងពីខាងលើ សុទ្ធតែគ្មានសុពលភាពទាំងអស់។ ដូច្នេះ ការដែលការកាត់ទោសលោក អៀង សារី ត្រូវបានធ្វើឡើង *ដោយកំបាំងមុខ* មិនអាចយកមកប្រើដើម្បីធ្វើមោឃភាពសាលក្រម ឆ្នាំ១៩៧៩ ឬ ដូចគ្នាដែរ ចំពោះព្រះរាជក្រឹត្យលើកលែងទោសនោះទេ។

៣១. ព្រះរាជក្រឹត្យលើកលែងទោស ត្រូវបានប្រទានឲ្យក្នុងគោលបំណងដើម្បីធានាថា លោក អៀង សារី បានទទួលការលើកលែងទោសចំពោះរាល់អំពើដែលចោទប្រកាន់នៅក្នុងសវនាការនាឆ្នាំ ១៩៧៩ ទាំងអស់ ដូច្នេះ រូបគាត់មិនត្រូវទទួលការផ្ដន្ទាទោសអ្វីទាំងអស់ចំពោះអំពើទាំងនេះ។ គិតត្រឹមកាលបរិច្ឆេទ ដែលព្រះរាជក្រឹត្យលើកលែងទោសត្រូវបានប្រទាន ទោសប្រហារជីវិតត្រូវបានលុបបំបាត់ចោលរួចទៅហើយនៅក្នុងប្រទេសកម្ពុជា[៤៧]។ ដូច្នេះ ព្រះមហាក្សត្រទ្រង់គ្មានចេតនាប្រទានព្រះរាជក្រឹត្យលើកលែងទោសនេះ ដើម្បីគ្រាន់តែធានាថា ទោសប្រហារជីវិតរបស់លោក អៀង សារី នឹងមិនត្រូវអនុវត្តនោះទេ។ ព្រះមហាក្សត្រទ្រង់អាចបានយល់រួចទៅហើយថា មិនចាំបាច់ត្រូវប្រទានព្រះរាជក្រឹត្យលើកលែងទោស ចំពោះអ្វីមួយដែលរដ្ឋធម្មនុញ្ញបានហាមប្រាម

---

http://www.thefreelibrary.com/_/print/PrintArticle.aspx?id+53002588; *អត្ថបទសារព័ត៌មាន* CNN WORLD *មានចំណងជើងថា៖ Coalition Agreement for Cambodia Comes with Royal Pardons,* ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ *អាចអានបាននៅគេហទំព័រ៖* http://articles.cnn.com/1998-11-13/world/9811_13_cambodia.01_1_coalition-government-pardons-new-coalition?_s=PM:WORLD; *អត្ថបទរបស់សារព័ត៌មាន* TAIPEI TIMES *មានចំណងជើងថា៖ Cambodia's PM Fires Two Officials in Cabinet Reshuffle*, ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ *អាចអានបាននៅគេហទំព័រ៖* http://www.taipeitimes.com/News/world/archives/2006/03/22/2003298602។

៤៦ *អត្ថបទព័ត៌មាន* BBC NEWS *មានចំណងជើងថា៖ Sam Rainsy Returns to Cambodia,* ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦, *អាចអានបាននៅគេហទំព័រ៖* http://news.bbc.co.uk/2/hi/asia-pacific/4699574.stm។

៤៧ *សូមមើល* សេចក្ដីសម្រេច ស្ដីពីបណ្ដឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ ឯកសារលេខ C22/1/73 កថាខណ្ឌ ៥៧។

រួចទៅហើយនោះទេ។ ប៉ុន្តែ ព្រះមហាក្សត្រទ្រង់នៅតែប្រទានការលើកលែងទោស។ ជាការសមហេតុសមផលសម្រាប់ការយល់ឃើញថា ព្រះមហាក្សត្រទ្រង់មានចេតនាធានាថា លោក អៀង សារី នឹងមិនទទួលការអនុវត្តទោសអ្វីទាំងអស់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទោស ដោយផ្អែកលើអំពើដែលត្រូវបានចោទប្រកាន់នៅក្នុងសវនាការឆ្នាំ១៩៧៩។ អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលស្គាល់លើចំណុចនេះភាគច្រើនផងដែរ នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា ខ្លួន "មិនបដិសេធលទ្ធភាពដែលថា ព្រះរាជក្រឹត្យនេះអាចមានបំណងលើកលែងទោស អៀង សារី ពីការអនុវត្តទោស និងការចោទប្រកាន់ពីបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តមុនឆ្នាំ១៩៩៦ និងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលមេធាវីការពារក្តីបានលើកឡើង"[៤៨]។ អនុលោមតាមគោលការណ៍ជាមូលដ្ឋានស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលចាំបាច់ត្រូវតែគោរពអនុលោមតាមរដ្ឋធម្មនុញ្ញ[៤៩] លទ្ធភាពនេះចាំបាច់ត្រូវតែពិចារណា ថាជាវិសាលភាពរបស់ព្រះរាជក្រឹត្យលើកលែងទោស។ ព្រះរាជក្រឹត្យលើកលែងទោស ចាំបាច់ត្រូវតែបកស្រាយថារារាំងលោក អៀង សារី ឲ្យរួចផុតពីការចោទប្រកាន់នាពេលបច្ចុប្បន្ននេះ។

**៥. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ព្រមទាំងរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានអនុវត្ត *អាជ្ញាអស់ជំនុំ* និងគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ***

៣២. ដោយហេតុថា សាលក្រមឆ្នាំ១៩៧៩ គឺជាសេចក្តីសម្រេចដ៏ត្រឹមត្រូវ អាចអនុវត្តបាន និងជាស្ថាពរ នោះគោលការណ៍ *អាជ្ញាអស់ជំនុំ* [៥០] ដូចមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

[៤៨] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៩។

[៤៩] រដ្ឋធម្មនុញ្ញ មាត្រា ៣៨។

[៥០] *Res judicata* មានន័យថា៖ "[ពាក្យឡាតាំង "រឿងដែលត្រូវបានវិនិច្ឆ័យ"] ១. បញ្ហាដែលត្រូវបានដោះស្រាយជាស្ថាពរតាមរយៈសេចក្តីសម្រេចរបស់តុលាការ ២. ការការពារជាវិជ្ជមានដែលរារាំងភាគីដដែល មិនឲ្យធ្វើពាក្យបណ្តឹងទីពីរស្តីពីការទាមទារដដែល ឬការទាមទារផ្សេងទៀត ដែលកើតចេញមកពីលទ្ធផលនៃការស្វែងរកដំណោះស្រាយមួយ ឬច្រើន ទោះបីជាការទាមទារនោះ អាចត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងទីមួយ ប៉ុន្តែខ្លួនមិនបានធ្វើយ៉ាងនេះក៏ដោយ។ ធាតុផ្សំសំខាន់បីយ៉ាងគឺ៖ (១) សេចក្តីសម្រេចមុនលើបញ្ហានេះ (២) សាលក្រមស្ថាពរសម្រេចលើអង្គសេចក្តី និង (៣) ភាពពាក់

កម្ពុជា[៥១] និងគោលការណ៍ជាអន្តរជាតិ ស្តីពី *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងក្នុងមាត្រា ១៤(៧) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រារាំងលោក អៀង សារី ឱ្យរួចផុតពីការចោទប្រកាន់នាពេលបច្ចុប្បន្ន[៥២]។

គោលការណ៍ច្បាប់របស់កម្ពុជា ស្តីពី *អាជ្ញាអស់ជំនុំ* ដូចមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនទទួលស្គាល់ករណីលើកលែងណាមួយទេ ដែលសវនាការនាពេលមុន មាន "ចំណុចខ្វះចន្លោះ" នោះ។ ករណីរបស់លោក អៀង សារី គឺជាករណី *អាជ្ញាអស់ជំនុំ* ។ ការកាត់សេចក្តីបច្ចុប្បន្ននេះជំនុំជម្រះលើបញ្ហាមួយដែលត្រូវបានដោះស្រាយរួចស្រេចទៅហើយនៅក្នុងសាលក្រមឆ្នាំ១៩៧៩[៥៣]។ ដូចលោក Klip និងលោក van der Wilt បានធ្វើការកត់សម្គាល់រួច

---

ព័ន្ធរបស់ភាគីដដែលឬភាគីដែលមានចំណាងទាក់ទងជាមួយនឹងភាគីដើមដំបូង..."។ BLACK"S LAW DICTIONARY 1312 (បោះពុម្ពផ្សាយលើកទី ៧ ឆ្នាំ១៩៩៩)។

៥១ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលស្គាល់ដោយត្រឹមត្រូវ មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលហាមឃាត់មិនឱ្យមានការជំនុំជម្រះថ្មី ដោយផ្អែកលើសកម្មភាពបង្កហេតុដដែល ចំពោះករណីដែលបុគ្គលនោះត្រូវបានសម្រេចឱ្យរួចផុតពីទោសជាស្ថាពរហើយនោះ មិនបានកំណត់ *អាជ្ញាអស់ជំនុំ* សម្រាប់គោលបំណងនៃមាត្រា៧ ឬដាក់កំហិតការអនុវត្តនេះទេ។ ផ្ទុយទៅវិញ មាត្រា ១២ ធានាថា គោលការណ៍ *អាជ្ញាអស់ជំនុំ* ត្រូវបានចែងយ៉ាងទូលំទូលាយ ដើម្បីគ្របដណ្តប់លើការសម្រេចឱ្យរួចខ្លួន និងស្ថានភាពដែលជនជាប់ចោទត្រូវបានចោទប្រកាន់ពីហេតុនៃអំពើដូចគ្នានឹង ហេតុនៅក្នុងករណីកាលពីមុន ប៉ុន្តែការអនុវត្តនេះអាស្រ័យទៅលើការកំណត់ប្រភេទបទល្មើសខុសៗគ្នា។ *សូមមើល* សេចក្តីសម្រេចដែលត្រូវបានជំទាស់ កំណត់សម្គាល់ជើងទំព័រលេខ ៦៤។ ការបកស្រាយមាត្រា ១២ នៅក្នុងករណីនេះ មិនមែនជាការចាំបាច់នោះទេ ដោយសារការជំនុំជម្រះក្តីនាពេលបច្ចុប្បន្នរបស់លោក អៀង សារី ត្រូវបានហាមឃាត់ដោយផ្អែកលើមាត្រា ៧។ *សូមមើលផងដែរ* សារណាបន្ថែមរបស់ លោក អៀង សារី លើអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ (*គោលការណ៍គ្មានការកាត់ទោសពីរដង ចំពោះបទល្មើសតែមួយ*) (*Ne Bis in Idem*), ឯកសារលេខ E51/11 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៤-១០។

៥២ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងពី៖ "ការរលត់នៃបណ្តឹងអាជ្ញា។ មូលហេតុនៃការរលត់បណ្តឹងអាជ្ញាមានដូចតទៅគឺ៖ ... ៥. *អាជ្ញាអស់ជំនុំ*។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ មិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់"។

៥៣ *សូមមើល* ឧបសម្ព័ន្ធ គ ភ្ជាប់ជាមួយ សារណារបស់ លោក អៀង សារី អនុលោមតាម *សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី សុំការពន្យាពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ញាយុត្តាធិការ* ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/26។ ឧបសម្ព័ន្ធនេះ ធ្វើការប្រៀបធៀប សាលក្រមឆ្នាំ១៩៧៩ ជាមួយសេចក្តីសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរ បង្ហាញឱ្យឃើញថា ឧក្រិដ្ឋកម្មនានា ដែលលោក អៀង សារី ត្រូវរងការចោទប្រកាន់ ជំនុំជម្រះ និង

ហើយថា៖ “វិធានច្បាប់តម្រូវថា ប្រសិនបើរដ្ឋបានចាប់ផ្តើមធ្វើការចោទប្រកាន់លើនរណាម្នាក់ ក្នុងចំណោមពលរដ្ឋរបស់ខ្លួន រដ្ឋនោះត្រូវគោរពលទ្ធផលនៃកិច្ចដំណើរការនីតិវិធី។ ហេតុដូច្នេះ សេចក្តីសម្រេចរបស់តុលាការត្រូវតែគោរពតាម។ ប្រសិនបើ *អាជ្ញាអស់ជំនុំ* មិនត្រូវបានគេចាត់ទុកជាស្ថាពរទេ វានឹងធ្វើឲ្យធម្មានុរូបរបស់រដ្ឋនោះធ្លាក់ចុះ”[៥៤]។

៣៣. ដោយហេតុថា កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាច្បាប់ដែលអាចយកមកអនុវត្តបាននៅក្នុងច្បាប់កម្ពុជា ហើយត្រូវតែគោរពអនុលោមតាមរដ្ឋធម្មនុញ្ញ កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានោះ គោលការណ៍ ស្តីពី *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងកតិការសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏អាចរារាំងការចោទប្រកាន់ទៅលើលោក អៀង សារី ដូចគ្នាផងដែរ។ គោលការណ៍នេះអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីតុលាការជាតិ ដូចជា អ.វ.ត.ក ជាដើម ប៉ុន្តែមិនត្រូវបានកម្រិតចំពោះតែកិច្ចដំណើរការនីតិវិធីជាតិទេ។ មិនមានចំណុចលើកលែងណាមួយត្រូវបានចែងទេចំពោះករណីមាន “ចំណុចខ្វះខាតនានា” នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលមុន។

៣៤. នៅក្នុងការកំណត់ថា គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នឹងមិនរារាំងការចោទប្រកាន់លើលោក អៀង សារី នាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា៖ “ការយកគោលការណ៍ *គ្មានការកាត់សេចក្តីពីរដងចំពោះបទល្មើសតែមួយ* គឺមានតម្លៃស្មើនឹងការអនុគ្រោះទោសតាម*ព្រឹត្តិន័យ* ចំពោះអង្គហេតុទាំងប៉ុន្មានដែលបានវិនិច្ឆ័យកាលពីឆ្នាំ ១៩៧៩”[៥៥]។ នៅពេលកំណត់ពីភាពអាចអនុវត្តបាន វាមិនមែនជាការត្រឹមត្រូវនោះទេក្នុងការពិចារណាថាតើការអនុវត្តគោលការណ៍ស្តីពី *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺជាការអនុគ្រោះទោស *តាមព្រឹត្តិន័យ* (*de facto*) មានន័យថា ត្រូវពិចារណាថាតើនឹងបណ្តាលឲ្យប៉ះពាល់ដល់

---

ផ្តន្ទាទោស គឺជាឧក្រិដ្ឋកម្មដដែល ដូចគ្នាទៅនឹងបទចោទរបស់គាត់ដែលមាននៅក្នុងសំណុំរឿង ០០២។ បទចោទទាំងនេះមានចែងនៅក្នុងដីកាដំណោះស្រាយ មិនបានបន្ថែមបទចោទ ដែលមិនបានចែងនៅក្នុងសាលក្រមឆ្នាំ១៩៧៩ ឡើយ។

[៥៤] សូមមើល Klip & van der Wilt ត្រង់ទំព័រ ១០៩៤។

[៥៥] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៣៦។

លទ្ធផលដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់ទុកជាមុនថាជា សេចក្តីសម្រេចដែលចង់បានខ្លាំងបំផុត ឬមួយយ៉ាងណា។ ការអនុវត្តធ្វើសេចក្តីសម្រេចដោយកំណត់យកលទ្ធផលទុកជាមុន ធ្វើឱ្យប៉ះពាល់ដល់ធម្មានុរូបនៃសារៈសំខាន់ក្នុងការបើកសវនាការជំនុំជម្រះមួយ ជាពិសេសនៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជានេះ ដោយសវនាការត្រូវប្រព្រឹត្តទៅក្នុងគោលបំណងអនុវត្តវិធានច្បាប់នៅគ្រប់ស្ថានការណ៍ និងភាពស្មុគស្មាញនានា ដោយមិនគិតថាតើលទ្ធផលនឹងបង្កឱ្យមានផលវិបាក ឬការមិនពេញចិត្ត ឬមួយយ៉ាងណានោះទេ។ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ហាក់ដូចជាមិនសមហេតុសមផលសោះ៖ អង្គជំនុំជម្រះសាលាដំបូងបកស្រាយ និងអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ក្នុងឥរិយាបថមួយដែលព្យាយាមផ្តល់យុត្តិកម្មទៅលទ្ធផលដែលខ្លួនចង់បាន ជាជាងធ្វើការបកស្រាយ និងអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នៅក្នុងឥរិយាបថមួយដើម្បីទទួលបានលទ្ធផលដោយយុត្តិធម៌ និងត្រឹមត្រូវ ទោះបីជាលទ្ធផលនោះ អាចនឹងបង្កឱ្យមានការមិនពេញចិត្ត ឬធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តក៏ដោយ។

៣៥. គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនជាប់ពាក់ព័ន្ធជាមួយការអនុគ្រោះទោសនោះទេ។ គោលបំណងរបស់គោលការណ៍នេះ គឺដើម្បីធានាឱ្យមានការគោរពចំពោះកិច្ចដំណើរការនីតិវិធីរបស់តុលាការ។ គោលការណ៍នេះ ត្រូវបានចាត់ថ្នាក់ជា "អនុសាធ្យនៃការទទួលស្គាល់អានុភាព *អាជ្ញាអស់ជំនុំ* នៃសាលក្រមផ្សេងទៀត ដែលមានបំណងការពារភាពស្ថាពរនៃសាលក្រម។ គំនិតនេះគឺថា នៅពេលដែលករណីមួយត្រូវបានសម្រេចរួចហើយ ករណីនេះមិនត្រូវបើកឱ្យដំណើរការឡើងវិញនោះទេ (ករណីត្រូវបានបញ្ចប់ *factum praeteritum*) ពីព្រោះទង្វើបែបនេះនឹងប៉ះពាល់ខ្លាំងដល់ការគោរពនីតិវិធីតុលាការ និងការគោរពតុលាការជាទូទៅ"[៥៦]។ អ.វ.ត.ក ចាំបាច់ត្រូវតែអនុវត្តធ្វើជាតុលាការ "គំរូ" សម្រាប់ប្រទេសកម្ពុជា តាមរយៈ

[៥៦] YASMIN Q. NAQVI, IMPEDIMENTS TO EXERCISING JURISDICTION OVER INTERNATIONAL CRIMES 307-08 (T.M.C. Asser Press 2010)។ គោលបំណងមួយទៀតនៃគោលការណ៍ ស្តីពី *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺដើម្បីធ្វើឱ្យបុគ្គលរួចផុតពីភាពតានតឹងពាក់ព័ន្ធនឹងផ្នែកចិត្តសាស្ត្រ ស្មារតី រូបរាងកាយ និងប្រាក់កាស ដែលទាក់ទិននឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌជាលើកទីពីរ។ គោលបំណងនេះមិនមែនគ្រាន់តែអនុវត្តចំពោះករណីដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចពីបទចោទនោះទេ។ ភាពតានតឹង និងការព្រួយបារម្ភ បណ្តាលមកពីការការចោទប្រកាន់ដែលកើត

ការគោរពប្រតិបត្តិតាមវិធានច្បាប់[៥៧]។ ដូច្នេះហើយ អ.វ.ត.ក ត្រូវតែគោរព និងអនុវត្ត គោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ដោយមិនចាំបាច់គិតថាតើ ផលប៉ះពាល់បណ្តាលមកពីការអនុវត្តគោលការណ៍នេះ នឹងមានលក្ខណៈស្មើគ្នាទៅនឹងការ អនុគ្រោះទោសដែរឬយ៉ាងណានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចទទ្បីករណ៍ដែលនឹង បង្ហាញជូន*ខាងក្រោម* នេះ គ្មានច្បាប់អន្តរជាតិណាមួយហាមឃាត់មិនឲ្យមានការអនុគ្រោះទោស ចំពោះឧក្រិដ្ឋកម្មនេះទេ។

## ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបានអនុវត្តព្រះរាជក្រឹត្យ អនុគ្រោះទោស ដើម្បីរារាំងមិនឲ្យមានការកាត់ទោសលោក អៀង សារី

៣៦. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ព្រះរាជក្រឹត្យអនុគ្រោះទោសមិនអាចផ្តល់អភ័យឯកសិទ្ធិ ដល់លោក អៀង សារី ឲ្យរួចផុតពីការកាត់ទោស អនុលោមតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ក្នុងការគោរពតាមសន្ធិសញ្ញា[៥៨] និងកាតព្វកិច្ចជាអន្តរជាតិដែលខ្លួន "មិនពិចារណាទៅលើការផ្តល់ ការអនុគ្រោះនោះទេ"[៥៩]។ អង្គជំនុំជម្រះសាលាដំបូង៖ **១.**រំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន

---

ឡើងម្តងហើយម្តងទៀត ធ្វើឲ្យប៉ះពាល់ដល់ក្រុមគ្រួសារ សាក្សី និងជនរងគ្រោះ ព្រមទាំងអាចនឹងធ្វើឲ្យស្ថានភាព កាន់តែធ្ងន់ធ្ងរ ដោយសារតែចំណាប់អារម្មណ៍ពីសំណាក់សារព័ត៌មាន។ *ឯកសារយោងមុន* ត្រង់ទំព័រ ៣០៧។

[៥៧] "អ.វ.ត.ក ត្រូវបានរៀបចំឡើងជាតុលាការគំរូមួយ សម្រាប់កំណែទម្រង់ផ្នែកតុលាការ និងផ្នែកច្បាប់កម្ពុជា"។ អនុសាសន៍ ពាក់ព័ន្ធនឹងតម្លាភាពបន្ថែមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដាក់ជូនដោយ សមាជិកសង្គមស៊ីវិល និងសមាជិកសាព័ត៌មាននៅកម្ពុជា ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨ *អាចអានបាននៅគេហទំព័រ* http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%20Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c788f6365e។ អង្គជំនុំជម្រះបាន ទទួលស្គាល់ពីគោលបំណងនេះ ព្រមទាំងបានទទួលយកភារកិច្ចទទួលខុសត្រូវរបស់ខ្លួន *តាមទ្រឹស្តី* (តាមរយៈសកម្មភាពដែលក្បត់នឹងចេតនារបស់ខ្លួន) នៅពេលដែលអង្គជំនុំជម្រះនាពេលថ្មីៗនេះ បានបញ្ជាក់ពីគោលជំហរនេះថ្លែងថា អ.វ.ត.ក "អាចជាតុលាការគំរូមួយ សម្រាប់ជួយជម្រុញឲ្យមាន ការធានានូវឯករាជ្យភាព និងសុច្ចរិតភាពនៅក្នុងស្ថាប័នតុលាការ" ហើយ អ.វ.ត.ក នឹងធានាថា "កិច្ចដំណើរការនីតិវិធី នឹងប្រព្រឹត្តទៅស្របតាមបទដ្ឋានអន្តរជាតិ"។ សេចក្តីសម្រេចលើ បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្តឹងជំទាស់ចិត្តចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E5/3 កថាខណ្ឌ ១៤-១៥។

[៥៨] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៣៨-៣៩។

[៥៩] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៤០-៥២, ៥៤។

ដោយសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យអនុគ្រោះទោស ២.មានកំហុសលើអង្គច្បាប់ក្នុងការសម្រេចថា កាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការគោរពសន្ធិសញ្ញា រារាំងព្រះរាជក្រឹត្យអនុគ្រោះទោស មិនឲ្យផ្ដល់អភ័យឯកសិទ្ធិដល់លោក អៀង សារី ឲ្យរួចផុតពីការចោទប្រកាន់នៅ អ.វ.ត.ក ៣.រំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនពិចារណាទៅលើព្រះរាជក្រឹត្យអនុគ្រោះទោស ដោយខ្លួនបានសន្និដ្ឋានថា ព្រះរាជក្រឹត្យអនុគ្រោះទោសផ្ទុយពីដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ៤.មានកំហុសលើអង្គច្បាប់ ដោយសន្និដ្ឋានថា ព្រះរាជក្រឹត្យអនុគ្រោះទោសរំលោភសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា។

## ១. អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យអនុគ្រោះទោសបានឡើយ

៣៧. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ព្រះរាជក្រឹត្យអនុគ្រោះទោសមិនអាចផ្ដល់អភ័យឯកសិទ្ធិដល់លោក អៀង សារី រួចផុតពីការកាត់ទោសទេ ដោយសារៈ ក.កាតព្វកិច្ចនៅក្នុងសន្ធិសញ្ញារបស់កម្ពុជា[៦០] និង ខ.កាតព្វកិច្ចជាអន្តរជាតិដែលខ្លួន "មិនពិចារណាលើការផ្ដល់នូវការអនុគ្រោះនោះទេ"[៦១]។ អង្គជំនុំជម្រះសាលាដំបូងបានបំពេញការងារ *ហួសពីសិទ្ធិអំណាចរបស់ខ្លួន (ultra vires)* ដោយសារការសន្និដ្ឋានទាំងនេះ ជាការសម្រេចទៅលើសុពលភាពរបស់ព្រះរាជក្រឹត្យអនុគ្រោះទោស។ កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក អនុញ្ញាតឲ្យ អ.វ.ត.ក ត្រឹមតែសម្រេចទៅលើ *វិសាលភាព* របស់ព្រះរាជក្រឹត្យអនុគ្រោះទោសតែប៉ុណ្ណោះ មិនមែនសម្រេចទៅលើសុពលភាពរបស់វាទេ[៦២]។

៣៨. ក្នុងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ទាំងមូល អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយធ្វើឲ្យមានការភាន់ច្រឡំរវាងពាក្យ "វិសាលភាព" និង "សុពលភាព"។ ពាក្យ "វិសាលភាព" មានន័យថា "អ្វីមួយដែលជាគោលដៅ ឬបំណងប្រាថ្នា អ្វីដែលបុគ្គលណាម្នាក់មានបំណងធ្វើឲ្យមាន

---

[៦០] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៣៨-៣៩។

[៦១] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៤០-៥២, ៥៤។

[៦២] *សូមមើល* កិច្ចព្រមព្រៀង, មាត្រា ១១(២)៖ "អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"; ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ៤០ថ្មី៖ "វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្ដល់ អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសំរេចដោយអង្គជំនុំជម្រះវិសាមញ្ញ"។

ប្រសិទ្ធភាពទៅលើ ឬសម្រេចឲ្យបាន ជាចំណុចចុងក្រោយនៃការមើលឃើញ ជាកម្មវត្ថុ គោលបំណង បំណងប្រាថ្នា"[៦៣]។ "វិសាលភាព" គឺជាបញ្ហាអង្គហេតុមួយ ជាការកំណត់នូវអ្វីដែលព្រះរាជក្រឹត្យអនុគ្រោះទោសមានបំណងនឹងគ្របដណ្ដប់ទៅលើ។ ទាក់ទិននឹងវិសាលភាពនៃព្រះរាជក្រឹត្យអនុគ្រោះទោសនោះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខ្លួន "មិនបដិសេធលទ្ធភាពដែលថា គោលបំណងរបស់វា ដូចដែលបានចោទប្រកាន់ដោយមេធាវីការពារក្ដីថា អាចជាការផ្ដល់អភ័យឯកសិទ្ធិដល់ អៀង សារី រួចផុតពីការអនុវត្តទោស និងការចោទប្រកាន់ពីបទល្មើសទាំងឡាយដែលបានប្រព្រឹត្តមុនឆ្នាំ ១៩៩៦ រួមទាំងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ"[៦៤]។

៣៩. ពាក្យថា "សុពល" មានន័យថា "ពេញលេញតាមផ្លូវច្បាប់"[៦៥]។ "សុពលភាព" គឺជាការសម្រេចតាមផ្លូវច្បាប់ ជាការសម្រេចថាតើព្រះរាជក្រឹត្យអនុគ្រោះទោសមានសុពលតាមផ្លូវច្បាប់ឬទេ។ អ.វ.ត.ក ពុំមានយុត្តាធិការដើម្បីសម្រេចពីបញ្ហានេះទេ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយពុំត្រឹមត្រូវថា ទោះជាតុលាការអន្តរជាតុបនីយកម្មក្ដី និង តុលាការជាតិក្ដី អាចទុកការអនុគ្រោះទោសដោយឡែក ឬកំហិតការអនុគ្រោះទោសបាន ប្រសិនបើការអនុគ្រោះទោសនោះត្រូវបានយល់ថាពុំស្របនឹងនិយមអន្តរជាតិ[៦៦] ក៏ដោយ ក៏ អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការកំណត់ពីភាពដែលអាចយកមកអនុវត្តបាននៃព្រះរាជក្រឹត្យអនុគ្រោះទោសទៅលើបទឧក្រិដ្ឋមួយចំនួននោះទេ។ តាមពិត អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា "ខ្លួនពុំមានតួនាទីសម្រេចអំពីសិទ្ធិអំណាចរបស់ព្រះមហាក្សត្រ និងសភាជាតិ ក៏ដូចជាសុពលភាពស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ឡើយ ដោយហេតុថា ការសម្រេចលើបញ្ហានេះជាបុព្វសិទ្ធិរបស់ក្រុម

---

[៦៣] វចនានុក្រម OXFORD ENGLISH DICTIONARY (បោះពុម្ពលើកទី២, ឆ្នាំ ១៩៨៩; សំណៅនៅលើអ៊ិនធឺណេត ខែ កញ្ញា ឆ្នាំ ២០១១), *អាចរកបាននៅគេហទំព័រ៖* http://www.oed.com/view/Entry/172974?rskey=Yfhs9S&result=2#eid។ ពាក្យថា "វិសាលភាព" ពុំមាននៅក្នុងវចនានុក្រម Black's Law Dictionary ទេ។

[៦៤] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ២៩។

[៦៥] វចនានុក្រម OXFORD ENGLISH DICTIONARY 1548 (បោះពុម្ពលើកទី៧, ឆ្នាំ ១៩៩៩)។

[៦៦] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៣។

ប្រឹក្សាធម្មនុញ្ញ”[៦៧]។

**២. កាតព្វកិច្ចសន្ធិសញ្ញារបស់ប្រទេសកម្ពុជាពុំរារាំងព្រះរាជក្រឹត្យអនុគ្រោះទោសមិនឲ្យផ្តល់អភ័យឯកសិទ្ធិដល់លោក អៀង សារី ឲ្យរួចផុតពីការចោទប្រកាន់នៅ អ.វ.ត.ក ទេ**

៤០. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា “ដោយសារតែប្រទេសកម្ពុជាជាប់កាតព្វកិច្ចដាច់ខាតក្នុងការធានាអំពីការចោទប្រកាន់ ឬការផ្តន្ទាទោសចារីនៃអំពើរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ អំពើប្រល័យពូជសាសន៍ និងការធ្វើទារុណកម្ម ព្រះរាជក្រឹត្យ [អនុគ្រោះទោស] ឆ្នាំ ១៩៩៦ មិនអាចដកប្រទេសកម្ពុជាពីកាតព្វកិច្ចក្នុងការកាត់ទោសបទឧក្រិដ្ឋទាំងអស់នេះ ឬបង្កើតជាឧបសគ្គចំពោះកាតព្វកិច្ចនេះបានទេ”[៦៨]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានបែបនេះ។ ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តច្បាប់ជាតិ ដើម្បីផ្តន្ទាទោសព្រហ្មទណ្ឌចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសជាក់លាក់នៅក្នុងអនុសញ្ញានីមួយៗ[៦៩]។ អនុសញ្ញាទីក្រុង

---

[៦៧] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ២៩។ សុពលភាពនៃច្បាប់ដែលត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រអាចត្រូវបានពិនិត្យធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ។ *សូមមើល* រដ្ឋធម្មនុញ្ញ, ពីមាត្រា ១៣៦ថ្មី ដល់មាត្រា ១៤៤ថ្មី។ ព្រះរាជក្រឹត្យ/ក្រមដទៃទៀតរបស់ព្រះមហាក្សត្រមិនអាចជំទាស់ដោយស្ថាប័នរដ្ឋបានឡើយ។ ចំណុចនេះកើតចេញពីមាត្រា ៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងថា អង្គព្រះមហាក្សត្រមិនអាចរំលោភបំពានបានឡើយ។

[៦៨] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៣៩។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយសន្និដ្ឋានថា “ដោយសារតែកាតព្វកិច្ចនៃសន្ធិសញ្ញារបស់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នេះ អង្គជំនុំជម្រះមិនត្រូវធ្វើការបកស្រាយព្រះរាជក្រឹត្យ [អនុគ្រោះទោស] ឆ្នាំ ១៩៩៦ ថាជា ការផ្តល់អភ័យឯកសិទ្ធិរួចផុតពីការកាត់ទោសជនជាប់ចោទ អៀង សារី ទាក់ទិននឹងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពីប្រល័យពូជសាសន៍ ឬការធ្វើទារុណកម្មនោះបានទេ”, *ដូចខាងលើ,* កថាខណ្ឌ ៣៨។

[៦៩] អនុសញ្ញាទីក្រុងហ្សឺណែវចែងថា៖ “រដ្ឋជាភាគីជាអ្នករៀបចំបង្កើតច្បាប់ដែលចាំបាច់ក្នុងការផ្តន្ទាទោសឲ្យមានប្រសិទ្ធភាពដល់បុគ្គលដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តអំពើបំពារបំពានធ្ងន់ធ្ងរណាមួយទៅលើអនុសញ្ញានេះដូចមានចែងនៅក្នុងមាត្រាខាងក្រោម”។ *សូមមើល* អនុសញ្ញាទីក្រុងហ្សឺណែវ I, មាត្រា ៤៩; អនុសញ្ញាទីក្រុងហ្សឺណែវ II, មាត្រា ៥០; អនុសញ្ញាទីក្រុងហ្សឺណែវ III, មាត្រា ១២៩; អនុសញ្ញាទីក្រុងហ្សឺណែវ IV, មាត្រា ១៤៦។ មាត្រា ៥ នៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទប្រល័យពូជសាសន៍ ដែលអនុម័តដោយសេចក្តីសម្រេចលេខ 260 (III) A របស់មហាសន្និបាត អ.ស.ប នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ ចូលជាធរមាននៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩៥១ ចែងថា៖ “អនុលោមតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន រដ្ឋជាភាគីជាអ្នករៀបចំបង្កើតច្បាប់ដើម្បីផ្តល់អានុភាពដល់អនុសញ្ញានេះ និងដោយឡែក ដើម្បីផ្តន្ទាទោសដល់បុគ្គលដែលមានពិរុទ្ធភាពពីបទប្រល័យពូជសាសន៍ ឬអំពើដទៃៗទៀតដែលមានរៀបរាប់នៅក្នុងមាត្រា III”។ មាត្រា ៥(២) នៃអនុសញ្ញា

ហ្សឺណែវ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម គឺជាសន្ធិសញ្ញារវាងប្រទេសកម្ពុជា និងបណ្តារដ្ឋដទៃទៀត កាតព្វកិច្ចរបស់ប្រទេសកម្ពុជាតាមសន្ធិសញ្ញាទាំងនេះមាននៅក្នុងប្រព័ន្ធច្បាប់អន្តរជាតិរវាងរដ្ឋ និងរដ្ឋ។

៤១. មានប្រព័ន្ធច្បាប់ជាតិមួយដោយឡែករវាងប្រទេសកម្ពុជា និងបុគ្គលនានាដែលរស់នៅក្នុងព្រំដែនរបស់ប្រទេសនេះ។ អង្គជំនុំជម្រះសាលាដំបូងធ្វើឲ្យមានការភាន់ច្រឡំរវាងកាតព្វកិច្ចតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជាចំពោះសហគមន៍អន្តរជាតិ និងកាតព្វកិច្ចតាមផ្លូវច្បាប់របស់ប្រទេសកម្ពុជាចំពោះបុគ្គលដែលរស់នៅក្នុងទឹកដីរបស់ខ្លួន។ នៅឆ្នាំ ១៩៩៦ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ព្រះរាជក្រឹត្យអនុគ្រោះទោស ប្រទេសកម្ពុជាមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមសន្ធិសញ្ញាដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ដែលមានចែងផ្តន្ទាទោសព្រហ្មទណ្ឌចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសជាក់លាក់នៅក្នុងអនុសញ្ញានីមួយៗទេ[៧០]។ ហេតុនេះ ព្រះរាជក្រឹត្យអនុគ្រោះទោសត្រូវបានផ្តល់ដោយមិនបានរំលោភដល់ច្បាប់ជាតិឡើយ។

៤២. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលសន្និដ្ឋានថា អ.វ.ត.ក អាចសម្រេចពីសុពលភាពរបស់ព្រះរាជក្រឹត្យអនុគ្រោះទោសបានក៏ដោយ ក៏កាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ មានភាពខុសគ្នាពីសិទ្ធិផ្តល់ឲ្យ និងសិទ្ធិក្នុងការតម្កល់ការអនុគ្រោះទោសឲ្យរួចផុតពីការកាត់ទោសចំពោះបទល្មើសទាំងនេះដែរ ប្រសិនបើកាតព្វកិច្ចបែបនោះពិតជាមានក៏ដោយ។ អ្នកប្រាជ្ញមួយរូបបានលើកឡើងថា "ច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលបច្ចុប្បន្ន*ពិតជា*ដាក់កាតព្វកិច្ចដល់បណ្តារដ្ឋនានា ឲ្យចោទប្រកាន់រាល់បទល្មើសសំខាន់ៗទាំងអស់ដែលបានប្រព្រឹត្តនៅក្នុង

---

ប្រឆាំងនឹងការធ្វើទារុណកម្មចែងថា៖ "រដ្ឋភាគីត្រូវផ្តន្ទាទោសចំពោះបទល្មើសទាំងនេះឲ្យបានសមស្រប តាមប្រភេទធ្ងន់ធ្ងរនៃបទល្មើសទាំងឡាយ"។

[៧០] សកម្មភាពដែលសមរម្យនៅក្នុងឧទាហរណ៍នេះគឺថា រដ្ឋមួយត្រូវប្តឹងប្រទេសកម្ពុជាទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ។ ករណីបែបនេះត្រូវតែប្តឹងដោយរដ្ឋជាភាគីមួយផ្សេងទៀតប្រឆាំងនឹងប្រទេសកម្ពុជា ដែលជាភាគីនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ *សូមមើល* អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា ៩។

យុត្តាធិការរបស់បណ្តារដ្ឋទាំងនោះ”[៧១] តែបានសន្និដ្ឋានថា ច្បាប់អនុគ្រោះទោសអាចនឹងត្រូវបានចាត់ទុកថាជា*ករណីលើកលែង*ចំពោះកាតព្វកិច្ចនេះ មិនមែនជាការរំលោភទៅលើកាតព្វកិច្ចនេះទេ[៧២]។ ឋានៈជា *អាជ្ញាព្រឹត្តិ* (jus cogens) នៃបទល្មើសក្រោមច្បាប់អន្តរជាតិ មិនបានផ្លាស់ប្តូរការវិភាគនេះទេ[៧៣]។ យុត្តាធិការថ្នាក់ជាតិមានអំណាចផ្តល់ឲ្យ និងសិទ្ធិក្នុងការតម្កល់ការអនុគ្រោះចំពោះបទល្មើសដែលមានលក្ខណៈ *អាជ្ញាព្រឹត្តិ* (jus cogens) ដោយសារការផ្តល់ឲ្យ និងតម្កល់ការអនុគ្រោះ គឺជាបញ្ហានៃអធិបតេយ្យភាពជាតិ និងច្បាប់ជាតិ[៧៤]។ ព្រះរាជក្រឹត្យអនុគ្រោះទោសអាច

---

[៧១] WARD N. FERDINANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS 202 (T.M.C. Asser Press 2006)។ Ferdinandusse គឺជាមន្ត្រីច្បាប់នៅនាយកដ្ឋានអយ្យការសាធារណៈហូឡង់ មានជំនាញផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

[៧២] *ដូចជើងទំព័រខាងលើ*, ត្រង់ទំព័រ ២០០។ Ferdinandusse កត់សម្គាល់ថា ការអនុគ្រោះទោសអាចត្រូវបានផ្សះផ្សារជាមួយកាតព្វកិច្ចក្នុងការចោទប្រកាន់បាន លុះត្រាតែលក្ខខណ្ឌនានានៃការអនុគ្រោះទោសឆ្លុះបញ្ចាំងនូវតុល្យភាពសមរម្យរវាងផលប្រយោជន៍ខុសៗគ្នាដែលពាក់ព័ន្ធ។ គាត់អះអាងថា “ការណ៍នេះត្រូវបានបង្ហាញឲ្យឃើញដោយលក្ខន្តិកៈតុលាការ ICC ដែលក្នុងន័យទូទៅបានទទួលស្គាល់ពីភាពចាំបាច់នៃការចោទប្រកាន់ តែក្នុងពេលជាមួយគ្នានោះវាក៏អនុញ្ញាតឲ្យមានអំណាចឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ដែរ ហើយវាមិនបាននិយាយអំពីគោលការណ៍នីត្យានុកូលភាព និងអានុភាពនៃការអនុគ្រោះទោសទេ ដោយសារបណ្តារដ្ឋដែលបានចូលរួមក្នុងការចរចាមិនបានសម្រេចនូវកិច្ចព្រមព្រៀងណាមួយលើបញ្ហានេះទេ”។ *ដូចជើងទំព័រខាងលើ*, ត្រង់ទំព័រ ២០១។

[៧៣] ក្រៅពីបញ្ហាថា ប្រទេសកម្ពុជាត្រូវអនុវត្តតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួននោះ ក.ស.ព ធ្លាប់បានលើកឡើងជាទឡ្ហីករណ៍រួចមកហើយគឺថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវឲ្យ អ.វ.ត.ក ពិចារណាទៅដល់ “បទដ្ឋានអន្តរជាតិ” មួយចំនួនដែលខ្លួនអះអាងថាបទដ្ឋានទាំងនោះមិនតម្រូវឲ្យយកព្រះរាជក្រឹត្យអនុគ្រោះទោសមកអនុវត្តទៅលើបទល្មើសនានាដែលមានលក្ខណៈ *អាជ្ញាព្រឹត្តិ* (jus cogens) ទេ។ ចំពោះការពិភាក្សាពីកំហុសនៃទឡ្ហីករណ៍នេះ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៧១-៧២។

[៧៤] ឧទាហរណ៍ កិច្ចព្រមព្រៀងនៅទីក្រុង Abidjan ជាកិច្ចព្រមព្រៀងមួយដែលបានផ្តល់ឲ្យនៅក្នុងយុត្តាធិការជាតិរបស់ប្រទេសសៀរ៉ាឡេអូន ដែលបានផ្តល់នូវការអនុគ្រោះទោសទាំងស្រុងដល់បទល្មើសទាំងឡាយដែលបានប្រព្រឹត្តដោយពួករណសិរ្សបង្រួបបង្រួមបដិវត្តន៍សៀរ៉ាឡេអូនកិច្ចព្រមព្រៀងទីក្រុង Abidjan បានធានា “ថាមិនមានការចោទប្រកាន់ផ្លូវការ ឬតាមផ្លូវតុលាការនឹងត្រូវធ្វើឡើងប្រឆាំងនឹងសមាជិកណាម្នាក់នៃពួក (“RUF”) ទាក់ទិននឹងអ្វីៗដែលអ្នកទាំងនោះបានប្រព្រឹត្តទៅតាមគោលដៅរបស់ខ្លួនក្នុងនាមជាសមាជិកនៃអង្គការនោះ រហូតមកទល់នឹងពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ”។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុង Abidjan រវាងរដ្ឋាភិបាលសាធារណរដ្ឋសៀរ៉ាឡេអូន និង រណសិរ្សបង្រួបបង្រួមបដិវត្តន៍សៀរ៉ាឡេអូន, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ (“កិច្ចព្រមព្រៀងទីក្រុង Abidjan”), មាត្រា ១៤ *អាចរកបាននៅគេហទំព័រ៖* http://www.sierra-leone.org/abidjanaccord.html។

ផ្តល់អភ័យឯកសិទ្ធិឲ្យរួចផុតពីការកាត់ទោសលោក អៀង សារី ទាក់ទិននឹងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម។

**៣. អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមាន ហើយមិនមែនអនុវត្តដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ**

**ក. ការអនុវត្តរបស់រដ្ឋ និង *សច្ចានុរណ៍ធម្មានុរូប* (opinio juris) ពុំហាមឃាត់ការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិទេ**

៤៣. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ខ្លួន “អាចអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនពិចារណាទៅលើការអនុគ្រោះទោសនេះ ដែលខ្លួនយល់ថាផ្ទុយទៅនឹងដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[៧៥]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានបែបនេះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន មិនមែនដូចអ្វីដែលខ្លួនយល់ថាជាដំណើរវិវឌ្ឍន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[៧៦]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានកំណត់និយមន័យដោយ ទម្លាប់អនុវត្តរបស់រដ្ឋ និង *សច្ចានុរណ៍ធម្មានុរូប* (opinio juris) “យ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង”[៧៧]។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “ទម្លាប់អនុវត្តរបស់រដ្ឋពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរផ្សេងៗក្រោមច្បាប់អន្តរជាតិ ពុំមានការស្របគ្នាទាំងស្រុងក្នុងការកំណត់អំពីការហាមឃាត់ដាច់ខាតមិនឲ្យមានការអនុគ្រោះទោសពាក់ព័ន្ធនឹងបទ

[៧៥] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៤។

[៧៦] ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “ការផ្តល់ការអនុគ្រោះទោសនៅតែជាទម្លាប់អនុវត្តជាប់ជាហូរហែក្តី ប៉ុន្តែក៏មាននិន្នាការក្នុងការកំហិតវិសាលភាពនៃការអនុគ្រោះទោសនេះដែរ”។ *ដូចជើងខាងលើ,* កថាខណ្ឌ ៥១។ “និន្នាការ” ពុំមែនជានិយាមអន្តរជាតិទេ។

[៧៧] *រឿងក្តី North Sea Continental Shelf Cases (ប្រទេសអាល្លឺម៉ង់ តទល់នឹង ប្រទេសដាណឺម៉ាក, ប្រទេសអាល្លឺម៉ង់ តទល់នឹង ប្រទេសហូឡង់), សាលក្រម, របាយការណ៍របស់តុលាការ I.C.J ឆ្នាំ ១៩៦៩,* ទំព័រ ៤៤, កថាខណ្ឌ ៧៧។

ល្មើសទាំងនោះក្តី”[៧៨]។ ការសន្និដ្ឋានបែបនេះត្រូវបានគាំទ្រដោយការពិនិត្យឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើការទទួលយក វិសាលភាព និងការអនុវត្តការអនុគ្រោះទោសនៅក្នុងបណ្តាប្រទេសដែលមានជម្លោះ និងក្រោយពេលជម្លោះផុតរលត់ទៅ ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអនុវត្តរបស់រដ្ឋចំនួន ២៨ ក្នុងរយៈពេលបីទសវត្សរ៍កន្លងមកនេះ រួមមានការអនុវត្តច្បាប់អនុគ្រោះទោស ដែលក្នុងនោះរដ្ឋ ១៨ បានគ្របដណ្តប់លើបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[៧៩]។ នាពេលថ្មីៗនេះ កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ

---

[៧៨] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៤។ ពាក្យថា “ផ្សេងទៀត” នៅក្នុងការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងយោងទៅដល់បទល្មើសក្រោមច្បាប់អន្តរជាតិដែលមិនគ្របដណ្តប់ដោយអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម។

[៧៩] *ដូចជើងទំព័រខាងលើ*, លេខ ១០៥ *ដែលដកស្រង់ចេញពី*ប្រទេសស៊ីលី (ក្រឹត្យច្បាប់ស្តីពីការអនុគ្រោះទោសឆ្នាំ ១៩៧៨ ដែលគ្របដណ្តប់ទៅលើបទល្មើសនានាដែលបានប្រព្រឹត្តនៅចន្លោះពីខែ កញ្ញា ឆ្នាំ ១៩៧៣ រហូតដល់ខែ មីនា ឆ្នាំ ១៩៧៨); ប្រទេសប្រេស៊ីល (ច្បាប់អនុគ្រោះទោសឆ្នាំ ១៩៧៩ ដែលគ្របដណ្តប់ទៅលើបទល្មើសដែលបានប្រព្រឹត្តនៅចន្លោះពីឆ្នាំ ១៩៦១ រហូតដល់ឆ្នាំ ១៩៧៤ លើកលែងតែអំពើភេរវកម្ម ការវាយប្រហារ និងការចាប់ជំរិត); ប្រទេសអាហ្សង់ទីន (ច្បាប់បញ្ចប់ (Full Stop Law) ឆ្នាំ ១៩៨៦ និងច្បាប់ស្តីពីការគោរពតាម (Due Obedience Law) ដែលគ្រប់ដណ្តបទៅលើបទល្មើសដែលបានប្រព្រឹត្តនៅមុនខែ ធ្នូ ឆ្នាំ ១៩៨៣ លើកលែងតែការរំលោភសេពសន្ថវៈ ការចាប់ជំរិត និងការលាក់បំពួនអនីតិជន ការផ្លាស់ប្តូរឋានៈជាជនស៊ីវិល និងការបម្រុងទុកនូវចលនវត្ថុតាមរយៈការរឹបអូសយក); ប្រទេសអ៊ុយរ៉ាហ្គាយ (ច្បាប់ស្តីពីមោឃភាពឆ្នាំ ១៩៨៦); ប្រទេសហុងឌុរ៉ាស់ (ក្រឹត្យច្បាប់លេខ៨៧-៩១ ឆ្នាំ ១៩៩១); ប្រទេសអែលសាលវ៉ាឌ័រ (ច្បាប់ស្តីពីការផ្សះផ្សារជាតិឆ្នាំ ១៩៩២ ក្រឹត្យច្បាប់លេខ ១៤៧ និង ច្បាប់ស្តីពីការអនុគ្រោះទោសជាទូទៅសម្រាប់ការពង្រឹងសន្តិភាពឆ្នាំ ១៩៩៣ ក្រឹត្យច្បាប់លេខ ៤៨៦ លើកលែងតែការចាប់ជម្រិត ការរឹបអូស និងសកម្មភាពដែលពាក់ព័ន្ធនឹងគ្រឿងញៀន); ប្រទេសម៉ូរីតានី (ច្បាប់ស្តីពីការអនុគ្រោះទោសឆ្នាំ ១៩៩៣); ប្រទេសកម្ពុជា (ច្បាប់ឆ្នាំ ១៩៩៤); ប្រទេសហៃទី (ច្បាប់ពាក់ព័ន្ធនឹងការអនុគ្រោះទោសឆ្នាំ ១៩៩៤); ប្រទេសប៉េរូ (ច្បាប់ស្តីពីការអនុគ្រោះទោសឆ្នាំ ១៩៩៥ លេខ ២៦៤៧៩); ប្រទេសអាហ្វ្រិកខាងត្បូង (ច្បាប់ស្តីពីការលើកស្ទួយឯកភាពជាតិ និងផ្សះផ្សារជាតិឆ្នាំ ១៩៩៥); Republika Srpska (ច្បាប់ស្តីពីការអនុគ្រោះទោសឆ្នាំ ១៩៩៦ និងច្បាប់ស្តីពីការការចោទប្រកាន់ទោសឆ្នាំ ១៩៩៩ និងវិសោធនកម្មច្បាប់ស្តីពីការអនុគ្រោះទោស); ប្រទេសសៀរ៉ាឡេអូន (កិច្ចព្រមព្រៀងទីក្រុង Abidjan ឆ្នាំ ១៩៩៦ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុង Lome ឆ្នាំ ១៩៩៩); ប្រទេសអ៊ុយហ្គង់ដា (ច្បាប់ស្តីពីការអនុគ្រោះទោសឆ្នាំ ២០០០); ប្រទេសអង់ហ្គោឡា (អនុស្សរណៈនៃការយល់ឃោគគ្នាស្តីពីសន្តិភាព និងការផ្សះផ្សារនៅក្នុងខេត្ត Cabinda ដែលត្រូវបានអនុម័តនៅក្នុងច្បាប់ស្តីពីការអនុគ្រោះទោសជាតិឆ្នាំ ២០០៦); ប្រទេសអាល់ហ្សេរី (ធម្មនុញ្ញស្តីពីសន្តិភាព និងការផ្សះផ្សារជាតិឆ្នាំ ២០០៥ លើកលែងតែការសម្លាប់រង្គាល ការរំលោភសេពសន្ថវៈ និងការទម្លាប់គ្រាប់បែកនៅទី

២០១១ រដ្ឋជាច្រើនបានផ្តល់អភ័យឯកសិទ្ធិចំពោះ *បទល្មើសដែលមានលក្ខណៈអាជ្ញាព្រឹត្តិ (jus cogens)*។ ប្រធានាធិបតីនៃប្រទេសយេម៉ែន Saleh បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលគាត់នឹងចុះចេញពីអំណាចជាថ្នូរនឹងការទទួលបានអភ័យសិទ្ធិឱ្យរួចផុតពីការចោទប្រកាន់ទោស។ អាជ្ញាធរយេម៉ែនត្រូវបានចោទប្រកាន់ថាបានវាយប្រហារទៅលើជនស៊ីវិល[៨០]។ ពុំមានបទល្មើសណាមួយត្រូវបានរារាំងដោយសារអភ័យឯកសិទ្ធិនេះទេ។ មានការរាយការណ៍ថា លោក **បាន គីមូន** អគ្គលេខាធិការអង្គការសហប្រជាជាតិបានថ្លែងថា គាត់ "ពេញចិត្តចំពោះការវិវឌ្ឍន៍ជាវិជ្ជមាននៃស្ថានភាពនៅប្រទេសយេម៉ែន"[៨១]។ ប្រសិនបើមានការអនុវត្តច្រើនបែបនេះដែលបង្ហាញថា រដ្ឋនានាបានអនុវត្តច្បាប់អនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ នោះមិនអាចមានទម្លាប់អនុវត្តរបស់រដ្ឋយ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែង ដែលកំណត់ពីការហាមឃាត់ដាច់ខាតមិនឱ្យការអនុគ្រោះទោសពាក់ព័ន្ធទៅនឹងបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិឡើយ។

៤៤. បន្ថែមទៅលើកង្វះទម្លាប់អនុវត្តរបស់រដ្ឋយ៉ាងទូលំទូលាយ និងមានឯកភាពគ្នាជាក់ស្តែងនោះ *សុភាធារណ៍ធម្មានុរូប (opinio juris)* ក៏គាំទ្រការប្រើការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិដែរ។ នៅឆ្នាំ ១៩៩៦ ជាឆ្នាំដែលផ្តល់ព្រះរាជក្រឹត្យអនុគ្រោះទោសនោះ រដ្ឋាភិបាលនៃប្រទេសសៀរ៉ាឡេអូនក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយរណសិរ្សបង្រួបបង្រួមបដិវត្តន៍សៀរ៉ាឡេអូន ("RUF") នៅទីក្រុង Abidjan ដែលផ្តល់នូវការអនុគ្រោះទោសទាំងស្រុងចំពោះបទល្មើសទាំងអស់ដែលបានប្រព្រឹត្តឡើយដោយពួក RUF ទាំងបទល្មើសក្រោមច្បាប់ជាតិ

---

សាធារណៈ); ប្រទេសហុងឌុរ៉ាស់ (ក្រឹត្យស្តីពីការអនុគ្រោះទោសឆ្នាំ ២០១០); ប្រទេសទុយនេស៊ី (ក្រឹត្យច្បាប់លេខ ២០១១-១ ដែលផ្តល់ការអនុគ្រោះទោសឆ្នាំ ២០១១)។

[៨០] *សូមមើលជាឧទាហរណ៍ Q&A: Yemen Crisis*, BBC NEWS, ចុះផ្សាយថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១, *អាចរកបាននៅគេហទំព័រ៖* http://www.bbc.co.uk/news/world-middle-east-14988945៖ "នៅខែ មិថុនា យន្តហោះរដ្ឋាភិបាលបានទម្លាក់គ្រាប់បែកទៅលើទីក្រុងនានាដែលគេហៅថាស្ថិតក្រោមការគ្រប់គ្រងរបស់ពួកយោធានៅខេត្ត Abyan ភាគខាងត្បូង ដោយបណ្តាលឱ្យមនុស្សរាប់ម៉ឺននាក់ត្រូវរត់ភៀសខ្លួន និងបានបន្តការវាយប្រហារទៅលើតំបន់នោះអស់រយៈពេលជាច្រើនខែ"។

[៨១] *Yemeni President Saleh signs deal on ceding power*, BBC NEWS, ផ្សាយថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១, *អាចរកបាននៅគេហទំព័រ៖* http://www.bbc.co.uk/news/world-middle-east-15858911។

និងក្រោមច្បាប់អន្តរជាតិ[៨២]។ អ.ស.ប អង្គការឯកភាពអាហ្វ្រិក, បណ្តារដ្ឋសហធន (the commonwealth) និងប្រទេសកូតឌីវ័រ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះក្នុងនាមជាអ្នកធានាផ្នែកស្មារតី[៨៣]។ នៅឆ្នាំ ១៩៩៣ អ.ស.ប បានរៀបចំការចរចាឱ្យមានកិច្ចព្រមព្រៀងស្តីពីការអនុគ្រោះទោសទាំងស្រុងមួយ ដើម្បីដោះស្រាយជម្លោះផ្ទៃក្នុងនៅប្រទេសហៃទី[៨៤]។ កិច្ចព្រមព្រៀងនោះរួមមានការអនុគ្រោះទោសដល់រដ្ឋាភិបាលយោធាជាថ្នូរនឹងការលើកប្រធានាធិបតី Aristide ឱ្យចូលកាន់តំណែងវិញ[៨៥]។ នៅឆ្នាំ ១៩៩៤ អ.ស.ប បានគាំទ្រឱ្យមានការអនុគ្រោះទោសនៅប្រទេសអាហ្វ្រិកខាងត្បូង[៨៦]។ ក្រោមផែនការអនុគ្រោះទោសដែលបានស្នើឡើងនោះ សមាជិកនៃកងកម្លាំងសន្តិសុខរបស់រដ្ឋាភិបាលអាប៉ាថេត និងពួកសកម្មជនអាប៉ាថេត នឹងបានទទួលបានអភ័យឯកសិទ្ធិទាំងស្រុង។ ជាថ្នូរមកវិញ រដ្ឋាភិបាលនឹងដោះលែងបណ្តាអ្នកទោសនយោបាយដែលនៅសេសសល់ទាំងអស់ឱ្យមានសេរីភាព[៨៧]។ នាពេលថ្មីៗនេះ នៅខែ ឧសភា ឆ្នាំ ២០១១ ប្រធានាធិបតីបារាំង Nicolas Sarkozy បានជំរុញជាសាធារណៈដល់អតីតមេដឹកនាំប្រទេសលីប៊ី វរៈសេនីយ៍ឯក Gaddafi ឱ្យចុះចេញពីតំណែង ដោយសារថា "ជម្រើសទាំងអស់នៅបើកចំហ"[៨៨]។ ជម្រើសទាំងអស់នោះរួមទាំងការអនុគ្រោះទោសផងដែរ។

៤៥. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ទម្លាប់អនុវត្ត[របស់រដ្ឋ]បង្ហាញជាអប្បបរមាអំពីសិទ្ធិជាប្រតិសកម្មរបស់រដ្ឋជាភាគីទីបី តុលាការអន្តរជាតុបនីយកម្ម និង តុលាការជាតិពាក់ព័ន្ធក្នុងការវាយតម្លៃទៅលើការអនុគ្រោះទោស និងទុកការលើកលែងទោសដោយឡែក ឬកំហិតវិសាលភាព

---

[៨២] កិច្ចព្រមព្រៀងទីក្រុង Abidjan, មាត្រា ១៤។

[៨៣] *ដូចជើងទំព័រខាងលើ*, មាត្រា ២៨។

[៨៤] Charles P. Trumbull IV, *Giving Amnesties a Second Chance*, 25 BERKELEY J. INT'L L. 283, 293-94 (ឆ្នាំ ២០០៨)។

[៨៥] *ដូចជើងទំព័រខាងលើ*។

[៨៦] *ដូចជើងទំព័រខាងលើ*, ត្រង់ទំព័រ ២៩៣។

[៨៧] *ដូចជើងទំព័រខាងលើ*។

[៨៨] *G8 Summit: Sarkozy Offers Libya's Gaddafi 'options'*, BBC NEWS, ផ្សាយថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១, *អាចរកបាននៅគេហទំព័រ៖* http://www.bbc.co.uk/news/world-europe-13564999។

នៃការអនុគ្រោះទោស ប្រសិនបើការអនុគ្រោះទោសនោះពុំស្របនឹងនិយមអន្តរជាតិ”[៨៩]។ ការសន្និដ្ឋាននេះមិនអាចយកមកអនុវត្តចំពោះព្រះរាជក្រឹត្យអនុគ្រោះទោសបានទេ។ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែសន្និដ្ឋានថា មានទម្លាប់អនុវត្តរបស់រដ្ឋចំពោះ “សិទ្ធិប្រតិសកម្ម” នេះ។ ទម្លាប់អនុវត្តរបស់រដ្ឋតែមួយមិនបង្កើតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ចាំបាច់ត្រូវតែមាន*សច្ចាធារណ៍ធម្មានុរូប* (opinio juris) ផង។ ទោះបី អ.វ.ត.ក ត្រូវបានចាត់ទុកជាតុលាការអន្តរជាតិ ឬតុលាការអន្តរជាតុបនីយកម្មដូចបានលើកឡើង*ខាងលើ* ក៏ដោយ ក៏ព្រះរាជក្រឹត្យអនុគ្រោះទោសមិនមែនមិនស្របទៅនឹងនិយាមអន្តរជាតិដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងដែរ[៩០]។

## ខ. លក្ខន្តិកៈ និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិពុំហាមឃាត់ការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិទេ

៤៦. អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើការសន្និដ្ឋានរបស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន (“SCSL”) ដែលថា SCSL “បានទទួលស្គាល់ “និយាមអន្តរជាតិច្បាស់លាស់ដែលមិនអនុញ្ញាតឲ្យរដ្ឋាភិបាលផ្តល់ការអនុគ្រោះទោស” ចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ ដោយសម្រេចថា ច្បាប់អន្តរជាតិពុំអនុញ្ញាតឲ្យមានការអនុគ្រោះទោសឡើយ។ ... តុលាការពិសេសសម្រាប់សៀរ៉ាឡេអូនបានកត់សម្គាល់ឃើញថា រដ្ឋមានកាតព្វកិច្ចចោទប្រកាន់បទល្មើសដែលមានលក្ខណៈ*អាជ្ញាព្រឹត្តិ* (jus cogens) ហើយការអនុគ្រោះទោសរបស់ប្រទេសសៀរ៉ាឡេអូន ពុំអាចគ្របដណ្តប់លើបទល្មើសនានាក្រោមច្បាប់អន្តរជាតិដែលជាកម្មវត្ថុនៃយុត្តាធិការសាកលបានឡើយ”[៩១]។ អង្គជំនុំជម្រះសាលាដំបូងមិនបានដោះស្រាយចំពោះអំណះអំណាងនានារបស់មេធាវីការពារក្តី ដែលថា SCSL មានកំហុសក្នុងការសន្និដ្ឋានបែបនេះនោះទេ[៩២]។ អង្គជំនុំជម្រះសាលា

---

[៨៩] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៣។

[៩០] និយាមអន្តរជាតិដែលអង្គជំនុំជម្រះសាលាដំបូងលើកយកមកសំអាងគឺកាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ និងកាតព្វកិច្ចក្នុងការផ្តល់ឲ្យជនរងគ្រោះនូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ *ដូចខាងលើ,* កថាខណ្ឌ ៥០-៥២។

[៩១] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៥៦។

[៩២] សារណាបន្ថែមរបស់លោក អៀង សារី លើអញ្ញត្រកម្មរបស់គាត់ ដែលធ្វើតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស), ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ E51/10, កថាខណ្ឌ២០-២៣។

ដំបូងមានកំហុសលើអង្គច្បាប់ចំពោះទិដ្ឋភាពជាច្រើន។ ទីមួយ ពុំមាននិយាមច្បាស់លាស់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដើម្បីធ្វើឲ្យការអនុគ្រោះទោស ឬការលើកលែងទោសដែលត្រូវបានផ្តល់ហើយនោះមានមោឃភាពទេ[៩៣]។ និយាមច្បាស់លាស់មិនមែនជានិយាមដែលមាននៅក្នុងច្បាប់អន្តរជាតិទេ។ ច្បាប់ជាធរមានគឺជាច្បាប់ដែលមានស្រាប់ មិនមែនជាទិសដៅដែលត្រូវចាត់ទុកថាធ្វើដំណើរឆ្ពោះទៅនោះទេ។ ទីពីរ ព្រះរាជក្រឹត្យអនុគ្រោះទោសពុំមែនជាការអនុគ្រោះទាំងស្រុងនោះទេ។ ព្រះរាជក្រឹត្យអនុគ្រោះទោសគឺសម្រាប់តែលោក អៀង សារី ម្នាក់ប៉ុណ្ណោះជាថ្នូរទៅនឹងការធ្វើសមាហរណកម្មរបស់គាត់ជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ទីបី នាពេលបច្ចុប្បន្ននេះពុំមាន

---

[៩៣] *សូមមើលជាឧទាហរណ៍* John Dugard, *Dealing with Crimes of a Past Regime. Is Amnesty Still an Option?*, 12 LEIDEN J. INT'L L. 1001, ១០០២-០៤ (ឆ្នាំ ១៩៩៩)៖ "នាពេលនេះ របបដែលបន្តពីនោះត្រូវបានផ្តល់យោបល់ដោយបណ្តាអ្នកស្រាវជ្រាវជាន់ខ្ពស់នានាដែលតំណាងសាធារណមតិ ពោលគឺអង្គការក្រៅរដ្ឋាភិបាល និងអ្នកស្រាវជ្រាវ ដែលថា របបថ្មីទាំងនោះមិនត្រឹមតែ*គួរតែ*ចោទប្រកាន់ប៉ុណ្ណោះទេ តែពួកគេត្រូវតែ*មានកាតព្វកិច្ច*ក្រោមច្បាប់អន្តរជាតិទៀតផងក្នុងការចោទប្រកាន់ ...។ ទស្សនៈនេះមានន័យថា ច្បាប់អន្តរជាតិហាមឃាត់ការអនុគ្រោះទោស។ ចំណុចនេះត្រូវបានបកស្រាយយ៉ាងច្បាស់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ នៅក្នុង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Furundžija ដែលសម្រេចថា ការអនុគ្រោះទោសចំពោះអំពើទារុណកម្មត្រូវមានមោឃភាព និងមិនបានទទួលការទទួលស្គាល់ពីបរទេសទេ។ *ទោះជាយ៉ាងណាក្តី គេមានការសង្ស័យថាតើច្បាប់អន្តរជាតិបានឈានមកដល់ដំណាក់កាលនេះហើយឬនៅ។* ទម្លាប់អនុវត្តរបស់រដ្ឋពិបាកនឹងគាំទ្រដល់វិធានបែបនេះណាស់ ដោយសារប្រវត្តិសាស្ត្រសម័យទំនើបពោរពេញទៅដោយឧទាហរណ៍នានាជាច្រើនស្តីពីករណីនានាដែលរបបគ្រប់គ្រងថ្មីបានផ្តល់ការអនុគ្រោះទោសដល់បណ្តាមន្ត្រីនានាពីរបបមុនៗដែលមានពិរុទ្ធភាពពីអំពើទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងចោទប្រកាន់អ្នកទាំងនោះ។ នៅក្នុងករណីបែបនេះជាច្រើន ដែលគួរឲ្យកត់សម្គាល់នោះគឺនៅប្រទេសអាហ្វ្រិកខាងត្បូង ដែលអង្គការសហប្រជាជាតិបានស្វាគមន៍ចំពោះដំណោះស្រាយបែបនេះ។ សេចក្តីសម្រេចរបស់តុលាការជាតិក៏អាចផ្តល់ភ័ស្តុតាងពីទម្លាប់អនុវត្តរបស់រដ្ឋដែរ។ ហើយនៅចំណុចនេះគេគួរសង្កត់ធ្ងន់ថា តុលាការធម្មនុញ្ញជាតិបានតម្កល់ជាទូទៅនូវច្បាប់អនុគ្រោះទោសដែរ ជួនកាលក៏បានសំដែងនូវទស្សនៈថា ច្បាប់អន្តរជាតិមិនត្រឹមតែខកខានមិនបានហាមឃាត់ការអនុគ្រោះទោសប៉ុណ្ណោះទេ តែក៏បានជួយជំរុញឲ្យមានការអនុគ្រោះទោសផងដែរ ដូចក្នុងករណីរបស់តុលាការនៅប្រទេសអាហ្វ្រិកខាងត្បូង និង អែលសាលវ៉ាឌ័រជាដើម" (គូសបញ្ជាក់បន្ថែម)។ *Leila Nadya Sadat*, *Exile, Amnesty and International Law*, 81 NOTRE DAME L. REV. 955, 1022 (ឆ្នាំ ២០០៦)៖ "លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងច្បាស់ចំពោះការជំទាស់មួយចំនួនទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ អភ័យឯកសិទ្ធិរបស់ប្រមុខរដ្ឋ និងអាជ្ញាយុកាលជាមួយដើម តែមិនបានចែងពីកាតព្វកិច្ចណាមួយក្នុងការចោទប្រកាន់ និងទាក់ទងទៅនឹងការអនុគ្រោះទោសទេ។ ទោះបីបញ្ហានេះត្រូវបានលើកឡើងក្នុងអំឡុងពេលមានសន្និសីទទីក្រុងរ៉ូម នៅពេលអនុម័តលក្ខន្តិកៈនេះក៏ដោយ ក៏ពុំមានមតិគាំទ្រជាឯកច្ឆ័ន្ទក្នុងចំណោមប្រតិភូចំពោះរបៀបនៃការដោះស្រាយនូវចំណោទបញ្ហានោះដែរ។ ចំណុចនេះក៏បានបង្ហាញផងដែរថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនមានភាពច្បាស់លាស់លើចំណុចនេះទេ យ៉ាងហោចណាស់នៅឆ្នាំ ១៩៩៨ ក៏មិនទាន់មានដែរ"។

និយាមនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលតម្រូវឲ្យរដ្ឋត្រូវផ្តន្ទាទោសចំពោះការប្រព្រឹត្តបទល្មើសដែលមានលក្ខណៈ*អាជ្ញាព្រឹត្តិ* (*jus cogens*) ឡើយ[៥៤]។ ប្រសិនបើបទល្មើសមួយមានឋានៈ*អាជ្ញាព្រឹត្តិ* (*jus cogens*) នោះ វាតម្រូវឲ្យរដ្ឋមិនត្រូវចូលពាក់ព័ន្ធនឹងបទល្មើសនេះទេ តែពុំចាំបាច់តម្រូវឲ្យរដ្ឋត្រូវផ្តន្ទាទោសចំពោះការប្រព្រឹត្តបទល្មើសនោះដែរ។ ប្រសិនបើការប្រព្រឹត្តបទល្មើសដែលមានលក្ខណៈ*អាជ្ញាព្រឹត្តិ* (*jus cogens*) ពុំបានទទួលឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេនោះ ការអនុគ្រោះទោសចំពោះបទឧក្រិដ្ឋដែលមានលក្ខណៈ*អាជ្ញាព្រឹត្តិ* (*jus cogens*) នេះមិនបណ្តាលឲ្យមានមោឃភាពឡើយ។ ទីបួន ដូចបានលើកឡើង*ខាងលើ*រួចមកហើយ ការអនុគ្រោះទោសដែលបានផ្តល់ចំពោះបទល្មើសតាមច្បាប់អន្តរជាតិជាកម្មវត្ថុនៃយុត្តាធិការសាកល។

៤៧. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "លក្ខន្តិកៈតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន និងតុលាការពិសេសសម្រាប់លីបង់ [("STL")] បានចែងថា ការអនុគ្រោះទោសដល់បុគ្គលទាំងឡាយដែលស្ថិតក្រោមយុត្តាធិការតុលាការជាតិនីមួយៗ ពុំត្រូវរារាំងដល់ការចោទប្រកាន់ណាមួយឡើយ"[៥៥]។ ការសន្និដ្ឋានបែបនេះរបស់អង្គជំនុំជម្រះសាលាដំបូងជាការគាំទ្រដល់អំណះអំណាងដែលថា ពុំមានច្បាប់ទំនៀមទម្លាប់អន្តរជាតិណាហាមឃាត់មិនឲ្យមានការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិទេ។ វាជាការពុំសមរម្យទេដែលលក្ខន្តិកៈតុលាការ SCSL និង STL មកហាមឃាត់ជាពិសេសមិនឲ្យមានការអនុគ្រោះទោសក្រោមយុត្តាធិការរបស់ខ្លួន ប្រសិនបើច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានបានហាមឃាត់មិនឲ្យមានការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិនោះ។ តុលាការអន្តរជាតិ/កូនកាត់/ដែលមានជំនួយពីអន្តរជាតិនីមួយៗ មានលក្ខន្តិកៈ ឬកិច្ចព្រមព្រៀងរបស់ខ្លួន ដែលលក្ខន្តិកៈ ឬកិច្ចព្រមព្រៀងមួយ

[៥៤] *សូមមើល* ANTONIO CASSESE, INTERNATIONAL CRIMINAL LAW 302 (Oxford University Press 2003)៖"ក្រៅពីនេះមិនមានវិធានទំនៀមទម្លាប់ណាមួយទទួលបានការគាំទ្រជាទូទៅទេ មិនមានគោលការណ៍អន្តរជាតិទូទៅណាមួយត្រូវបានគេរកឃើញដែលអាចយកមកធ្វើជាសំអាងដើម្បីបង្ហាញថា កាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសក្រោមច្បាប់អន្តរជាតិត្រូវបានបង្ហាញច្បាស់ដោយសហគមន៍អន្តរជាតិទេ"។ សម្រាប់ជាការវិភាគបន្ថែមទៅលើចំណុចនេះ, *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ១២៦-២៩។

[៥៥] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៤៧។

ចំនួនប៉ុណ្ណោះដែលមានចែងពីការអនុគ្រោះទោស[៥៦]។ ពុំមានមាត្រាណាមួយនៅក្នុងលក្ខន្តិកៈតុលាការ ICTY ឬ ICTR ដែលហាមឃាត់មិនឲ្យមានការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ដែលស្ថិតក្រោមយុត្តាធិការតុលាការរបស់ខ្លួននោះទេ។ នៅ អ.វ.ត.ក គេអាចសម្រេចបានតែទៅលើវិសាលភាពនៃព្រះរាជក្រឹត្យអនុគ្រោះទោសប៉ុណ្ណោះ[៥៧]។

**គ. យុត្តិសាស្ត្រតុលាការជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានលើកមកសំអាងមិនអាចបង្កើតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអនុញ្ញាតឲ្យតុលាការទុកជាមោឃៈដោយប្រតិសកម្ម ឬកំហិតពីការអនុគ្រោះទោសទេ**

៤៨. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "តុលាការប្រទេសស៊ីលី អាហ្សង់ទីន អ៊ុយរ៉ាហ្គាយ ហុងឌូរ៉ាស ប៉េរូ និងកូឡុំប៊ី សុទ្ធតែបានចាត់ទុកជាមោឃៈនូវច្បាប់អនុគ្រោះទោសទាំងស្រុង ឬបានកំហិតវិសាលភាពនៃការអនុវត្តច្បាប់ទាំងអស់នោះ"[៥៨]។ សេណារីយ៉ូនេះខុសគ្នាស្រឡះពីព្រះរាជក្រឹត្យអនុគ្រោះទោស។ ព្រះរាជក្រឹត្យអនុគ្រោះទោសពុំមែនជាការអនុគ្រោះទោសទាំងស្រុងទេ វាអនុវត្តតែចំពោះលោក អៀង សារី តែម្នាក់ប៉ុណ្ណោះ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចាត់ទុកជាមោឃៈនូវច្បាប់អនុគ្រោះទោសទាំងស្រុងដោយប្រតិសកម្ម ឬដែលកំហិតពីសុពលភាពតាមផ្លូវច្បាប់ មិនអាចត្រូវបានបង្កើតឡើងតាមរយៈការអនុវត្តរបស់តុលាការថ្នាក់ជាតិនៃរដ្ឋចំនួន ៦ បានទេ។

**ឃ. បើសិនបើលក្ខខណ្ឌទាំងនោះពិតជាមានមែន លោក អៀង សារី ប្រាកដជាឆ្លើយតបទៅនឹងលក្ខខណ្ឌ**

---

[៥៦] សម្រាប់ការពិភាក្សាពីមូលហេតុដែលតុលាការ SCSL ខុសគ្នាស្រឡះពី អ.វ.ត.ក និងពីមូលហេតុដែលសេចក្តីសម្រេចរបស់តុលាការ SCSL មិនទទួលស្គាល់ការអនុគ្រោះទោសបទល្មើសដែលមានលក្ខណៈ *អាជ្ញាក្រឹត្តិ (jus cogens)* មិនបានបង្ហាញថាការអនុគ្រោះទោសចំពោះបទល្មើសទាំងនេះមានមោឃភាព, *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៧៥-៨២។

[៥៧] កិច្ចព្រមព្រៀង, មាត្រា ១១(២)៖ "អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ"; ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៤០ថ្មី៖ "វិសាលភាពនៃការលើកលែងទោស ឬ អនុគ្រោះទោសដែលអាចត្រូវបានផ្តល់ អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសំរេចដោយអង្គជំនុំជម្រះវិសាមញ្ញ"។

[៥៨] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥៩។

**ទាំងនោះដើម្បីទទួលបានការអនុគ្រោះទោសមិនខាន**

៤៩. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ទោះបីនាពេលកន្លងមក ការអនុគ្រោះទោសទាំងស្រុងគឺជានិយាមមួយក្តី ក៏ការអនុគ្រោះទោសជាច្រើនពុំបានគ្របដណ្តប់លើបទល្មើសធ្ងន់ធ្ងរមួយចំនួនក្រោមច្បាប់អន្តរជាតិឡើយ ...។ វដ្តធម្មនុញ្ញនៃបណ្តាប្រទេសកាន់តែច្រើនឡើង មានចែងអំពីការហាមឃាត់ការអនុគ្រោះទោសចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិ"[៩៩]។ ការសន្និដ្ឋានបែបនេះពុំអាចយកមកប្រើចំពោះព្រះរាជក្រឹត្យអនុគ្រោះទោសបានទេ។ ព្រះរាជក្រឹត្យអនុគ្រោះទោស ដែលត្រូវបានអនុម័តដោយរដ្ឋសភា (ដែលមានសមាជិកជាអ្នកតំណាងអ្នកបោះឆ្នោត) បានបញ្ចេញសម្តែងបង្ហាញពីឆន្ទៈរបស់ប្រជាជន *មិនមែន*ជាការលើកលែងទោសទាំងស្រុងទេ[១០០]។ វាមានការកំហិតច្បាស់លាស់គឺថា៖ វាអនុវត្តចំពោះលោក អៀង សារី *តែម្នាក់* ប៉ុណ្ណោះ ហើយវាក៏មិនបានដកហូត ឬធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីទេ ដោយសារវាមិនបានរារាំងដល់ការចោទប្រកាន់ដល់អ្នកដទៃទៀតឡើយ។ វដ្តធម្មនុញ្ញក៏ពុំបានហាមឃាត់មិនឲ្យបានការអនុគ្រោះទោស ចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិដែរ[១០១]។

៥០. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអនុគ្រោះទោសក្រោមលក្ខខណ្ឌមួយចំនួនត្រូវបាន "ទទួលស្គាល់ ឬរហូតដល់លើកទឹកចិត្តជាបន្តបន្ទាប់"[១០២]។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញនូវឧទាហរណ៍ពីការអនុគ្រោះទោសដែលជាថ្នូរទៅនឹងអង្គហេតុនានា "ដែលធានាយ៉ាងហោចណាស់ឲ្យមានការទទួលខុសត្រូវមួយចំនួន និងឲ្យជនរងគ្រោះបានដឹងការពិត"[១០៣] និង "ការចុះចូលជាមួយអាជ្ញាធរ"[១០៤]។ ស្រដៀងគ្នានេះដែរ ជាការថ្នូរទៅនឹងព្រះរាជក្រឹត្យអនុគ្រោះទោសនោះ

---

[៩៩] *ដូចជើងទំព័រខាងលើ*។

[១០០] *Sihanouk Pardons Ieng Sary*, BANGKOK POST, ច្បាប់ចេញផ្សាយថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦៖ "ហ៊ុន សែន និយាយថា វាជាការងាយទេដែលត្រូវដើរប្រមូលហត្ថលេខាពីសមាជិករដ្ឋសភាក្នុងចំណោមរដ្ឋសភាដែលមានសមាជិក ១២០ រូបនោះ ..."។

[១០១] វដ្តធម្មនុញ្ញ, មាត្រា ២៧, ៩០ថ្មី។

[១០២] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៥២។

[១០៣] *ដូចជើងទំព័រខាងលើ*។

[១០៤] *ដូចជើងទំព័រខាងលើ*។

លោក អៀង សារី បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ដែលបានបញ្ចប់សង្គ្រាមស៊ីវិល រយៈពេល ១៧ ឆ្នាំយ៉ាងជោគជ័យ និងបានផ្តល់ជនរងគ្រោះនូវលទ្ធភាពបានដឹងការពិត តាមរយៈការបោះពុម្ពផ្សាយឯកសារដែលមានចំណងជើងថា "ការពិតអំពីរបបផ្តាច់ការរបស់ប៉ុលពត"។

## ៤. ព្រះរាជក្រឹត្យអនុគ្រោះទោសពុំរំលោភទៅលើកាតព្វកិច្ចសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជាទេ

៥១. អង្គជំនុំជម្រះសាលាដំបូងបានសំអាងទៅលើធម្មនុញ្ញតុលាការយោធាអន្តរជាតិ ("IMT") និងតុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE") លក្ខន្តិកៈតុលាការ ICC លក្ខន្តិកៈតុលាការ ICTY និងលក្ខន្តិកៈតុលាការ ICTR ជាលិខិតុបករណ៍អន្តរជាតិដែលដាក់កាតព្វកិច្ចចោទប្រកាន់បទល្មើសក្រោមច្បាប់អន្តរជាតិ[១០៥]។ ដូចបានលើកឡើង*ខាងលើ* គឺថា កាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ មានភាពខុសគ្នាពីសិទ្ធិក្នុងផ្តល់ឲ្យ និងសិទ្ធិក្នុងការតម្កល់ការអនុគ្រោះទោសរួចផុតពីការកាត់ទោសចំពោះបទល្មើសទាំងនេះដែរ ប្រសិនបើកាតព្វកិច្ចបែបនោះមានមែននោះ។ ធម្មនុញ្ញតុលាការ IMT ធម្មនុញ្ញតុលាការ IMTEF លក្ខន្តិកៈតុលាការ ICTY លក្ខន្តិកៈតុលាការ ICTR និង លក្ខន្តិកៈតុលាការ ICC ពុំបានចែងថាតើការអនុគ្រោះទោសអាចត្រូវបានផ្តល់ចំពោះបទល្មើសក្រោមច្បាប់អន្តរជាតិឬយ៉ាងណានោះទេ។ ហេតុនេះ ទាក់ទិននឹងករណីថា តើការអនុគ្រោះទោសរំលោភ ឬមិនរំលោភដល់កាតព្វកិច្ចរបស់រដ្ឋក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិនោះ លិខិតុបករណ៍អន្តរជាតិទាំងនេះមិនអាចបង្កើតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ។

---

[១០៥] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៤១។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា លក្ខន្តិកៈតុលាការ ICC "បានបញ្ជាក់អះអាងជាថ្មីអំពីភាពចាំបាច់ ដែលត្រូវជំនុំជម្រះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ" *ដូចខាងលើ*។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា លក្ខន្តិកៈតុលាការ ICTY និង ICTR "បញ្ជាក់យ៉ាងច្បាស់នូវប្រភេទនៃបទល្មើសដែលត្រូវចោទប្រកាន់ និងផ្តន្ទាទោសជាចាំបាច់" *ដូចជើងខាងលើ,* កថាខណ្ឌ ៤៧។ អង្គជំនុំជម្រះសាលាដំបូងក៏បានអះអាងផងដែរថា តុលាការ ICTY "ក៏បានសម្រេចផងដែរថា "[ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារវិសាលភាព និងស្ថានទម្ងន់នៃអំពើទាំងនេះចេញហួសឆ្ងាយពីការកំហិតដែលអាចទទួលយកបានដោយសហគមន៍អន្តរជាតិដែលទាមទារឲ្យមានការផ្តន្ទាទោសជាការចាំបាច់"" *ដោយបានដកស្រង់ចេញពី រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Erdemovic,* សំណុំរឿងលេខ IT-96-22-T, សាលក្រមផ្តន្ទាទោស, ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, កថាខណ្ឌ ២៨; *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundzija,* សំណុំរឿងលេខ IT-95-17/1-T, សាលក្រម, ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨, កថាខណ្ឌ១៥៥-៥៦។

៥២. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអនុគ្រោះទោសចំពោះចារីនៃបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ មានវិសមិតភាពទៅនឹងកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងក្នុងការចោទប្រកាន់អំពើទាំងអស់នេះ[១០៦]។ ព្រះរាជក្រឹត្យអនុគ្រោះទោសពុំរំលោភទៅលើកាតព្វកិច្ចក្នុងការស៊ើបអង្កេត និងការចោទប្រកាន់អំពើឧក្រិដ្ឋនានាដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ("DK") នោះទេ។ ទីមួយ សំណុំរឿង ០០២ ត្រូវបានស៊ើបអង្កេតរួចហើយ។ ដីកាដំណោះស្រាយ ដែលជាឯកសារសាធារណៈ ត្រូវបានចេញដោយស្ថាប័នឯករាជ្យ និងមិនលម្អៀងនៅ អ.វ.ត.ក គឺ សហចៅក្រមស៊ើបអង្កេត[១០៧] ដែលមានកាតព្វកិច្ច "ស្វែងរកការពិត"[១០៨]។ ទីពីរ ព្រះរាជក្រឹត្យអនុគ្រោះទោសអនុវត្តចំពោះលោក អៀង សារី តែម្នាក់ប៉ុណ្ណោះ។ ទីបី ដោយសារសំណុំរឿង ០០២ ពាក់ព័ន្ធនឹងជនជាប់ចោទដទៃទៀតនោះ ព្រះរាជក្រឹត្យអនុគ្រោះទោសពុំរាំងមិនឲ្យចោទប្រកាន់ចំពោះអំពើនានាដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

៥៣. អង្គជំនុំជម្រះសាលាដំបូងបានលើកឧទាហរណ៍នានាពីតុលាការ IACtHR តុលាការសិទ្ធិមនុស្សអឺរ៉ុប និងគណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន ដែលបានសន្និដ្ឋានថាច្បាប់អនុគ្រោះទោសមានវិសមិតភាពជាមួយអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់ស្ថាប័នទាំងនោះ[១០៩]។ ឧទាហរណ៍ទាំងនេះបានកើតឡើងចាប់ពីឆ្នាំ ១៩៨៨ រហូតឆ្នាំ ២០១០[១១០]។ រដ្ឋនីមួយៗដែលត្រូវបានគេកោះហៅមកបំភ្លឺ នៅចំពោះមុខតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ ត្រូវតែបានអនុវត្តការអនុគ្រោះទោស ឬច្បាប់អនុគ្រោះទោស ដើម្បីធ្វើឲ្យអាចចោទជាសំណួរចំពោះសុពលភាពនៃការអនុគ្រោះទោស ឬច្បាប់អនុគ្រោះទោសទាំងនេះ។ នេះជាការបង្ហាញពីទម្លាប់អនុវត្តរបស់រដ្ឋ ដែលជាធាតុផ្សំមួយ

[១០៦] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៣៨។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានបន្ថែមទៀតថា ប្រភពបន្ទាប់បន្សំផ្សេងៗនៃច្បាប់អន្តរជាតិ "បានទទួលស្គាល់កាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់ជាតិ និងវិសមិតភាពនៃការអនុគ្រោះទោសចំពោះបទល្មើសទាំងនេះ..."។ *ដូចខាងលើ*, កថាខណ្ឌ ៤៨។

[១០៧] មាត្រា ៥(៣)នៃកិច្ចព្រមព្រៀងចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតបានឡើយ"។

[១០៨] វិធាន ៥៥(៥) ចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់"។

[១០៩] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ៤៣-៤៥។

[១១០] *ដូចជើងទំព័រខាងលើ*, លេខ ៩១-៩៦។

យ៉ាងសំខាន់សម្រាប់បង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងការប្រកាសឲ្យប្រើការអនុគ្រោះទោស ឬច្បាប់អនុគ្រោះទោស។ ទម្លាប់អនុវត្តរបស់រដ្ឋអនុញ្ញាតឲ្យអនុវត្តការអនុគ្រោះទោសចំពោះបទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ។

៩៤. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា កាតព្វកិច្ចចោទប្រកាន់ពីបទល្មើសក្រោមច្បាប់អន្តរជាតិ និងវិសមិតភាពនៃការអនុគ្រោះទោសនានាចំពោះបទល្មើសទាំងនេះ "ឆ្លុះបញ្ចាំងថែមទៀតពីទស្សនៈរបស់រដ្ឋភាគច្រើននៃសហគមន៍អន្តរជាតិ"[១១១]។ អង្គជំនុំជម្រះសាលាដំបូង *មិនបាន* គាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួននេះទេ។ ទម្លាប់អនុវត្តរបស់រដ្ឋជាច្រើននៅក្នុងសហគមន៍អន្តរជាតិពុំឆ្លុះបញ្ចាំងពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងនេះទេ[១១២]។ ដូចបានកត់សម្គាល់ *ខាងលើ* រួចមកហើយ គឺថា បណ្តារដ្ឋ និង អ.ស.ប ប្រកាន់ជំហរទៅតាមស្ថានភាពជាក់ស្តែង ហើយជ្រើសរើសយកការអនុគ្រោះទោសក្នុងករណីចាំបាច់។

៩៥. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ការអនុគ្រោះទោស ដែលរារាំងចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ ពុំស្របទៅនឹងកាតព្វកិច្ចអន្តរជាតិរបស់រដ្ឋក្នុងការផ្តល់ឲ្យជនរងគ្រោះនៃអំពើរំលោភបំពានទាំងអស់នូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពទេ[១១៣]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានបែបនេះ។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់នូវសំអាង ឬឯកសារយោងណាមួយសម្រាប់ការសន្និដ្ឋាននេះទេ។ ទីពីរ សិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព នៅក្នុងករណីនេះ ពុំចាំបាច់តម្រូវឲ្យមានការចោទប្រកាន់លោក អៀង សារី នោះទេ។ ព្រះរាជក្រឹត្យអនុគ្រោះទោសអាចយកទៅអនុវត្តបាន ដោយពុំរំលោភទៅលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការផ្តល់ឲ្យជនរងគ្រោះនូវដំណោះស្រាយដោយប្រសិទ្ធភាពនោះទេ។ សំណុំរឿង ០០២ ត្រូវបានស៊ើបអង្កេតរួចហើយ ហើយអាចនឹងមានការចោទប្រកាន់ចំពោះជនជាប់ចោទដទៃទៀតដែរនៅក្នុងសំណុំរឿង ០០២។ ឯកសាររបស់លោក អៀង សារី ដែលបានបោះពុម្ពផ្សាយមានចំណងជើងថា "ការពិតអំពីរបបផ្តាច់ការរបស់ប៉ុលពត" បានផ្តល់នូវការទទួលខុសត្រូវ និងឲ្យជនរងគ្រោះបានដឹងការពិត។ ព្រះរាជក្រឹត្យអនុគ្រោះទោសបានបញ្ចប់សង្គ្រាម

---

[១១១] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៤៨។

[១១២] *ដូចជើងទំព័រខាងលើ,* លេខ ១០៥។

[១១៣] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៤២។

ស៊ីវិលដែលមានរយៈពេល ១៧ ឆ្នាំ ដែលបានរារាំងមិនឲ្យមានជនរងគ្រោះបន្ថែមទៀតដោយសារសង្គ្រាមស៊ីវិល។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានដឹងពីបញ្ហានេះច្បាស់ដែរ[១១៤]។

## VI. សេចក្តីសន្និដ្ឋាន

៥៦. សេចក្តីសម្រេចដែលត្រូវបានជំទាស់ ត្រូវតែទុកជាមោឃៈ ហើយការចោទប្រកាន់លោក អៀង សារី ត្រូវតែបញ្ចប់ភ្លាម។ អង្គជំនុំជម្រះសាលាដំបូង ដែលពុំមានសមត្ថកិច្ច និងពុំមានអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចពីសុពលភាពនៃសាលក្រមឆ្នាំ ១៩៧៩ ឬព្រះរាជក្រឹត្យលើកលែងទោសនោះ មានកំហុសដោយសន្និដ្ឋានថា សាលក្រមឆ្នាំ ១៩៧៩ ពុំមានសុពលភាពទេ។ កំហុសនេះនាំឲ្យអង្គជំនុំជម្រះនេះខកខានមិនបានអនុវត្តព្រះរាជក្រឹត្យលើកលែងទោសដែលមានសុពលភាព និងច្បាប់កម្ពុជាជាធរមាន ដើម្បីធានាថា លោក អៀង សារី ពុំបានអនុវត្តទោសចំពោះអំពើនានានៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ។ នេះជាវិសាលភាពរបស់ព្រះរាជក្រឹត្យលើកលែងទោស។ ប្រសិនបើមានវិមតិសង្ស័យពីវិសាលភាពនេះ វិមតិសង្ស័យនោះនឹងត្រូវដោះស្រាយដោយផ្តល់ប្រយោជន៍ដល់លោក អៀង សារី។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀត ដោយខកខានមិនបានអនុវត្តគោលការណ៍ *គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ (ne bis in idem)* ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និង ICCPR។ បទប្បញ្ញត្តិ *អាជ្ញាអស់ជំនុំ (res judicata)/គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ (ne bis in idem)* នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា និង ICCPR ជាច្បាប់កម្ពុជាមានសុពលភាព និងជាធរមាន ហើយពុំមានការលើកលែងណាមួយ ដែលអាចកំហិតពីការអនុវត្តបទប្បញ្ញត្តិទាំងនេះនៅក្នុងករណីនេះឡើយ។

៥៧. អង្គជំនុំជម្រះសាលាដំបូងបានបំពេញការងារ *ហួសពីសិទ្ធិអំណាចរបស់ខ្លួន (ultra vires)* ដោយបានសម្រេចអំពីសុពលភាពរបស់ព្រះរាជក្រឹត្យអនុគ្រោះទោស។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលសន្និដ្ឋានថា មានការឯកភាពគ្នាថ្មីៗដែលហាមឃាត់ការអនុគ្រោះទោសចំពោះបទ

[១១៤] "បើ អៀង សារី មិនដឹកនាំកម្លាំង [ខ្មែរក្រហម] ចំពោះ ៧០% មកធ្វើសមាហរណកម្មចូលរួមជាមួយកងកម្លាំងរដ្ឋាភិបាលទេនោះ យើងប្រហែលជាមិនអាចបញ្ចប់សង្គ្រាមបានទេ", *Khmer Rouge Trial Law on Track for December Approval: Cambodian PM*, AGENCE FRANCE-PRESSE, ច្បាប់ចេញផ្សាយថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០០។

ល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ[១១៥]។ ការឯកភាពគ្នាថ្មីៗមិនមែនជានិយាមអន្តរជាតិច្បាស់លាស់ទេ។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានយ៉ាងត្រឹមត្រូវថា "ទម្លាប់អនុវត្តរបស់រដ្ឋពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរផ្សេងៗក្រោមច្បាប់អន្តរជាតិ ពុំទាន់មានការស្របគ្នាទាំងស្រុងក្នុងការកំណត់អំពីការហាមឃាត់ដាច់ខាតមិនឱ្យអនុគ្រោះទោសពាក់ព័ន្ធនឹងបទល្មើសទាំងនោះ"[១១៦]។ មិនត្រឹមតែទម្លាប់អនុវត្តរបស់រដ្ឋមិនពេញលេញប៉ុណ្ណោះទេ *សទ្ធាធារណ៍ធម្មានុរូប (opinio juris)* ក៏ពុំពេញលេញដែរ។ ការហាមឃាត់ដាច់ខាតការអនុគ្រោះទោសមិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។

៩៨. កាតព្វកិច្ចរបស់ប្រទេសកម្ពុជាតាមអនុសញ្ញាទីក្រុងហ្សឺណែវ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្ម គឺត្រូវអនុវត្តច្បាប់ជាតិ ដើម្បីផ្តន្ទាទោសដល់បុគ្គលដែលបានប្រព្រឹត្តបទល្មើសជាក់លាក់ទាំងនេះនៅក្នុងអនុសញ្ញានីមួយៗ។ កាតព្វកិច្ចទាំងនេះពុំមែនជាការហាមឃាត់ដាច់ខាតការអនុគ្រោះទោសដែលទាក់ទិននឹងអំពើប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម និងការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ នោះទេ។ ព្រះរាជក្រឹត្យអនុគ្រោះទោសពុំមានវិសមិតភាពជាមួយកាតព្វកិច្ចក្នុងការចោទប្រកាន់បទល្មើសធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិ និងកាតព្វកិច្ចក្នុងការផ្តល់ឱ្យជនរងគ្រោះនូវសិទ្ធិទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនោះឡើយ។

## VII. សំណូមពរ

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គបុរេជំនុំជម្រះសូមមេត្តា៖

ក. **សន្និដ្ឋានថា** បណ្តឹងសាទុក្ខនេះអាចទទួលយកបាន។

ខ. **យល់ព្រមឱ្យមាន**សវនាការផ្ទាល់មាត់ជាសាធារណៈ។

គ. **ទុកជាមោឃៈ**នូវសេចក្តីសម្រេចដែលត្រូវបានជំទាស់។ និង

ឃ. **បង្គាប់**ឱ្យបញ្ចប់ការចោទប្រកាន់លោក អៀង សារី ភ្លាម។

---

[១១៥] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ ៥៣។

[១១៦] *ដូចដើងទំព័រខាងលើ*។

សូមដាក់ជូនដោយក្តីគោរព

អាង ឧត្តម | Michael G. KARNAVAS

សហមេធាវីការពារលោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៥** ខែ **ធ្នូ** ឆ្នាំ **២០១១**